សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា
KhmerPost USA
E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 978-942-1641

មាតិការរឿង **Issue 174 06th - 24th April, 2015** **Free**

១-ទស្សនៈអ្នកក្រុងឡូវែលអំពីអាស៊ី....................០២
២-ការបោះឆ្នោតនៅវត្តត្រៃរតនារាម....................០៤
៣-បុណ្យអ៊ីស្ទើរ....................០៥
៤-សំណើរឱ្យលុបកិច្ចព្រមព្រៀង "ក្រុងបងប្អូន"........០៦
៥-"កុំស្មានបងភ្លេច" ខ្មែរបាត់បង់តន្ត្រីករ....................០៧
៦-បទសម្ភាសន៍ជាមួយលោក គីម សុខា....................០៨
៧-អំពីទីក្រុងនៅតំបន់....................០៩
៨-លោក ហង្ស ពុទ្ធា អ្នកសង្កេតការណ៍បោះឆ្នោត.....១០

**Office:** Tel: (978) 677-7163 Fax: (978) 677-7092
45 Merrimack St. Suite 218A Lowell, MA 01852




# ឆ្នាំមមែក្នុងទំនាយមហាសង្ក្រាន្ត






នៅក្នុងមហាសង្ក្រាន្តឆ្នាំមមែ ឆ្នាំពពែ របស់គណៈកម្មាធិការស្រាវជ្រាវហោរាសាស្ត្រ និងប្រពៃណីទំនៀមទម្លាប់ខ្មែរនៃក្រសួងធម្មការ និងកិច្ចការសាសនា ដែលរៀបរៀង និងគណនាដោយលោក អ៊ឹម បុរិន្ទ អគ្គលេខាធិការរងគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិអន្តរជាតិ និងជាគណៈកម្មការស្រាវជ្រាវវិជ្ជាហោរាសាស្ត្រ និងប្រពៃណីទំនៀមទម្លាប់ខ្មែរនោះ គឺមហាសង្ក្រាន្តឆ្នាំថ្មី២០១៥នឹងចូលមកដល់ចំថ្ងៃអង្គារ ១១ រោជ ខែចេត្រ **តទៅទំព័រទី ៣១**

## វិចារណកថា

### ចរចាជាមួយបិសាច


ពិន សំខុន

**ដោយ ពិន សំខុន**

ខិតខំចរចាប្រាថ្នាឱ្យបាន "ច្បាប់បោះឆ្នោត" មួយដែលគ្រប់ភាគីនយោបាយអាចប្រើបានដោយស្មើមុខនឹងអាចទទួលយកបានអាចឆ្លុះបញ្ចាំងនូវភាពសុច្ចរិតគឺជាគោលការណ៍មួយដែលប្រកបដោយក្រឹត្យក្រមសីលធម៌ពេញលក្ខណៈ គឺជាសភាវធម៌នៃក្រុម "ទេវតា" ដែលតាមថែរក្សា **តទៅទំព័រទី ២០**

### "The Deal with Demon"

**By Pin Samkhon**

A sense of sincerity is reflected in a negotiation for "the new Election Laws" for all. When common interest is considered it reflects a morally comprehensive principle of the "Theravadas" who protectshuman beings.However if the same negation has a hidden agenda which is aimed to sabotage the laws for the sake of one own party's victory

**Continued to Page 20**

REMEDIUM PHARMACY
ឱសថស្ថានរ៉េមីឌៀម
2 Vinal Square. North Chelmsford, MA 01863
ជាឱសថស្ថានបំរើការគ្រប់យ៉ាងដល់អ្នក
• ផ្ទេរឬផ្លាស់ប្តូរសេវាកម្ម
• ការវេចខ្ចប់ឱសថ
• ការលាយផ្សំឱសថ
• បញ្ជូនឱសថដល់ផ្ទះដោយឥតគិតថ្លៃ
• ជួយធ្វើសំបុត្រទិញថ្នាំ
• ផ្លាស់ប្តូរយោបល់ដោយរាក់ទាក់
ឱសថស្ថានយើងខ្ញុំនិយាយភាសាខ្មែរ
FREE daily delivery | Bliterpack Packging | Compounding Medicaction
Friendly consultations | Easy Transfers
Tel: 978-251-7070 | Fax: 978-251-7071



# ទស្សនៈអ្នកក្រុងឡូវែលអំពីអាស៊ី

## ខ្មែរផុស ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥



Richard Howe Jr.

**ដោយ** Richard P. Howe Jr.
**ប្រែសម្រួលដោយ មួង ណារ៉េត**

មិនខុសពីមនុស្សភាគច្រើនដែលកើតនៅក្រុងឡូវែលក្នុងទសវត្សឆ្នាំ១៩៥០ និង១៩៦០ ខ្ញុំធ្លាប់ដឹងតិចតួចណាស់អំពីអាស៊ី។ ពីមុនមកខ្ញុំមិនសូវបានយល់ដឹងច្រើនអំពីវប្បធម៌ជាតិសាសន៍អាស៊ីនេះទេ។ ទើបតែឥឡូវនេះប៉ុណ្ណោះដែលខ្ញុំយល់ដឹងច្រើន។ កាលពីមុនខ្ញុំមិនសូវបានដឹងដោយសារភាគច្រើននៃជនអន្តោប្រវេសន៍ដែលមករស់នៅទីក្រុងឡូវែល កាលមុនទសវត្សឆ្នាំ១៩៨០ គឺសុទ្ធតែអ្នកមកពីប្រទេសអឺរ៉ុប។ ម្យ៉ាងដោយសារទីក្រុងឡូវែលស្ថិតនៅតំបន់ឆ្នេរខាងកើតនៃសហរដ្ឋអាមេរិកម្ល៉េះ ហើយអ្នកក្រុងឡូវែលដូចខ្ញុំចាប់អារម្មណ៍ប្រទេសអឺរ៉ុបដោយស្វ័យប្រវត្តិ។

ជាអកុសលដោយសារជម្លោះអន្តរជាតិ ដូចជាសង្គ្រាមលោកលើកទី២ សង្គ្រាមកូរ៉េ ការដួលរលំនៃរបបកុម្មុនីស្តនៅប្រទេសចិន និងសង្គ្រាមវៀតណាម ទើបធ្វើឱ្យប្រជាជនអាស៊ីមានគំនិតអវិជ្ជមានមកលើជនជាតិអាមេរិកជាទូទៅ។ នេះជារឿងធម្មតាត្បិតមនុស្សតែងតែមានគំនិតអរិភាពទៅលើគូបដិបក្ខពេលធ្វើសង្គ្រាម។ ប៉ុន្តែការរើសអើងពូជសាសន៍ ក៏ជាកត្តាបណ្តាលឱ្យមានគំនិតអរិភាពនេះដែរ។ ទោះបីជប៉ុន និងអាល្លឺម៉ង់ ធ្លាប់ជាគូសត្រូវរបស់អាមេរិកយ៉ាងណាក៏ដោយក៏ជនជាតិអាមេរិកចាត់ទុកជនជប៉ុនក្នុងផ្លូវអវិជ្ជមានខ្លាំងជាងជនជាតិអាល្លឺម៉ង់។ ជនជាតិអាមេរិក៥ម៉ឺននាក់បានស្លាប់ក្នុងសង្គ្រាមវៀតណាម។ ក្នុងនោះមានអ្នកក្រុងឡូវែល១៩នាក់ផងដែរ។ ប៉ុន្តែរដ្ឋាភិបាលអាមេរិកនៅតែមិនអាចពន្យល់ឱ្យប្រជាជនអាមេរិកជឿបាននៅឡើយ ថាតើសង្គ្រាមនោះមានសារប្រយោជន៍អ្វីខ្លាំងម្ល៉េះ រហូតដល់ពលីជីវិតមនុស្សចំនួនសន្ធឹកយ៉ាងដូច្នេះ។

ការយល់ឃើញអំពីអាស៊ីចាប់ផ្តើមផ្លាស់ប្តូរភ្លាមៗ បន្ទាប់ពីសង្គ្រាមវៀតណាមរលត់។ នៅមុននោះបន្តិចរាល់ផលិតផលដែលនាំមកពីប្រទេសជប៉ុន និងប្រទេសអាស៊ីដទៃទៀត ត្រូវបានគេចាត់ទុកថាជារបស់"អន់"។ មានន័យថា ផលិតផលទាំងនោះជាទំនិញថោក និងអន់គុណភាព។ ទោះជាយ៉ាងនេះក្តីនៅឆ្នាំ១៩៧៤ មានបញ្ហាប្រឈមមួយកើតឡើងពីការខ្វះប្រេងឆៅ និងសាំងដោយសារតែប្រទេសនៅអារ៉ាប់ដាក់ទណ្ឌកម្មផ្អែកនាំចេញទំនិញមកអាមេរិក។ ភ្លាមនោះស្រាប់តែរថយន្តតូច ដូចជាប្រភេទរថយន្ត តូយូតា របស់ជប៉ុន និង Datsun (សព្វថ្ងៃហៅថា នីសាន់) ចាប់ផ្តើមមានប្រជាប្រិយភាពដោយសាររថយន្តទាំងនេះស៊ីសាំងតិច និងប្រើធន់មិនងាយខូច។ ក្រុមហ៊ុនអាស៊ីឯទៀត ដូចជា សូនី និងសាំស៊ុង ចាប់ផ្តើមលក់ផលិតផលមានគុណភាពខ្ពស់ក្នុងតម្លៃសមរម្យក្នុងទីផ្សារអាមេរិក។




ប្រជាជនអាស៊ីអាគ្នេយ៍ដំបូងៗដែលមកកាន់ទីក្រុងឡូវែលមិនសូវទទួលបានការចាប់អារម្មណ៍ពីសំណាក់ប្រជាជនអាមេរិកទេ។ ប៉ុន្តែនៅពេលជនជាតិអាស៊ីទាំងនេះ កាន់តែបន្តមកច្រើនឡើងៗ អ្នកស្រុកឡូវែលចាប់ផ្តើមចាប់អារម្មណ៍ទៅលើពួកគេ។ អង្គការ ដូចជាក្រុមរបាំអង្គរ និងសមាគមខ្មែរ (CMAA) បានខិតខំយ៉ាងអនេក ដើម្បីលើកស្ទួយវប្បធម៌ខ្មែរ និងអាស៊ី ដើម្បីឱ្យប្រជាជនដទៃទៀតនៅក្រុងឡូវែលដែលមិនមែនជាជនជាតិអាស៊ីបានយល់ដឹងអំពីវប្បធម៌ខ្មែរ និងអាស៊ី។ បច្ចុប្បន្ននេះគេអាចស្វែងយល់អំពីជនជាតិអាស៊ី និងវប្បធម៌អាស៊ីនៅតាមសាលារៀន អគារពាណិជ្ជកម្ម និងភោជនីយដ្ឋាន និងនៅតំបន់ក្រុងឡូវែល។ ទាំងនេះ គឺជាសមិទ្ធិដែលកើតចេញពីកិច្ចខិតខំប្រឹងប្រែងរបស់ប្រជាជនខ្មែរក្នុងក្រុងឡូវែលដែលបានជួយឱ្យទីក្រុងនេះប្រែក្លាយជាទីឋានគាប់ប្រសើរមួយសម្រាប់មនុស្សគ្រប់គ្នា៕

# A Lowell Resident's View of Asia

KhmerPost USA - April 3, 2015

**By Richard P. Howe Jr.**

Like most people who grew up in Lowell in the 1950s and 1960s, I knew very little about Asia and did not appreciate Asian culture the way I do today. Because most of the immigrants who came to Lowell before the 1980s were from Europe and because of the city's location on the East Coast of the United States, Lowell residents were naturally interested in Europe.

Unfortunately, international conflicts such as World War Two, the Korean War, the fall of China to the Communists and the Vietnam War combined to create a negative impression of Asia in the minds of many Americans. It is natural to demonize your opponent in war but racism also contributed to this. Americans held a much more negative view of the Japanese than they did of the Germans even though both had been our enemies. Fifty thousand Americans died in the Vietnam War, including 19 from Lowell, yet the American Government failed to convince the American people that the objectives of that war were worth that sacrifice.

Perceptions of Asia began to change soon after the Vietnam War ended. Before that, products from Japan and other Asian countries were considered "cheap" meaning they were inexpensive and poorly made. In 1974, however, there was a shortage of oil and gasoline due to an embargo against America by Arab nations. Suddenly, small Japanese cars like the Toyota and the Datsun (today called Nissan) became popular because of their fuel efficiency and reliability. Other Asian companies like Sony and Samsung began selling high quality products at affordable prices.

The first Southeast Asian people who came to Lowell attracted little notice but as their numbers grew, long-time Lowell residents began to notice. Organizations like the Angkor Dance Troupe and the Cambodian Mutual Assistance Association did much to promote Cambodian and Asian culture among non-Asian Lowell residents. Everyday contacts in school, at businesses and restaurants and in the neighborhood have allowed many Lowell residents to learn much about Asian people and Asian culture. This is another way that the Cambodian people who came to Lowell have helped make the city a better place for everyone.

# ព្រះអង្គម្ចាស់ធម្មិកោ : សង្គ្រោះជាតិមានយុទ្ធសាស្ត្រដើម្បីដឹកនាំប្រទេស

**តពីលេខមុន**

**ដោយ ស្តាយ បុណ្យ**

ស្ថាប័នព្រះមហាក្សត្រខ្សោយ រម្លាយសង្គមជាតិយើងបំផ្លាញសាសនារបស់យើង។ ទាំងអស់នេះហើយជាស្ថានការណ៍នៅក្នុងប្រទេសជាតិយើង"



### តើយើងធ្វើយ៉ាងម៉េចដើម្បីរកដំណោះស្រាយ ?

ព្រះអង្គផ្តល់នូវចម្លើយយ៉ាងនេះថា: "ដំណោះស្រាយមានតែមួយ គឺរួបរួមគ្នាដើម្បីរំដោះប្រទេសជាតិយើង។ តើរំដោះតាមផ្លូវណា? តាមផ្លូវឆ្នោត។ អាវុធរបស់យើង គឺសន្លឹកឆ្នោតរបស់យើង។ គណបក្សសង្គ្រោះជាតិមានសង្ឃឹមយ៉ាងមុតមាំដោយសារប្រជារាស្ត្រនៅតាមមូលដ្ឋានបានយល់ច្បាស់គេមិនបាក់ទឹកចិត្តទេ គេមិនអស់សង្ឃឹមទេ" ដូនជីនៅវត្តគោកសំពៅ ស្រុកព្រះស្តេចព្រៃវែង បានផ្តាំថា "ព្រះអង្គពួកខ្ញុំបានបោះឆ្នោតឱ្យសង្គ្រោះជាតិទាំងអស់គ្នា។ យើងទាំងអស់គ្នានឹងបោះឆ្នោតឱ្យសង្គ្រោះជាតិតទៅទៀត។ យើងសុំតែមួយមុខសុំកុំឱ្យបែកបាក់គ្នា។ អ្នកមូលដ្ឋានមានសង្ឃឹមតែទៅលើសង្គ្រោះជាតិមួយមុខគត់។ សូមទុកចិត្តនៅលើឆន្ទៈប្រជារាស្ត្រនៅមូលដ្ឋានដែលប៉ងចង់បានតែមួយគត់ គឺផ្លាស់ប្តូរ និងចង់រំដោះជាតិយើងពីអំណាចរបស់យួន។ នេះហើយជាសង្ឃឹមរបស់យើង" ។

ចំពោះបញ្ហាការបញ្ចូលកងអាវុធហត្ថកងទ័ពប៉ូលិសជនជាតិយួនពាក់ស័ក្តិខ្មែរ ព្រះអង្គម្ចាស់ធម្មិកោយល់ថា: "ក្នុងក្រសួងធំៗពេលសង្គ្រោះជាតិឈ្នះយើងនឹងយកច្បាប់សញ្ជាតិ និងអន្តោប្រវេសន៍មកអនុវត្ត។ ត្រូវតែមានព្រះរាជក្រឹត្យផ្តល់ ទើបជនបរទេសអាចក្លាយទៅជាខ្មែរបាន។ យើងត្រូវស្រាវជ្រាវរកអ្នកដែលមានអត្តសញ្ញាណប័ណ្ណខ្មែរ តើអ្នកនោះ មានព្រះរាជក្រឹត្យតែងតាំងខ្លួនឯងជាខ្មែរ ឬអត់? ក្នុងជួរយោធា និងរាជការយើងមានច្បាប់ដែរ។ ពេលសង្គ្រោះជាតិឈ្នះឆ្នោតយើងនឹងពិនិត្យមើលតើអ្នកទាំងនោះ បានប្រឡងចូលក្នុងជួររាជការត្រឹមត្រូវឬអត់។ យើងឈឺចាប់ដោយមានជំនាញការយួនមកត្រួតត្រាយើង។ កុំភ្លេចអ្នកដែលធ្វើរាជការកងកម្លាំងប្រដាប់អាវុធដែលត្រូវយួនត្រួតត្រាពួកគាត់សុទ្ធតែឈឺចាប់ដូចយើងដែរ។

**តទៅទំព័រទី២៧**

# The 5th Annual

KhmerPost USA

# Media & Community Gala

## Celebrating Asian/Pacific American Heritage Month

Friday, May 8th, 2015 at 6:30PM-Midnight.

Pailin Restaurant. 6 Branch St. Lowell, Massachusetts 01851

# រាត្រីសមោសរប្រចាំឆ្នាំ ខួបទី ៥

ប្រព័ន្ធផ្សព្វផ្សាយ និង សហគមន៍

**ដើម្បីអបអរទិវាស្នាដៃជនជាតិអាមេរិកដើមកំណើតអាស៊ី**

**ប្រារព្ធនៅថ្ងៃសុក្រទី៨ ខែឧសភា ឆ្នាំ២០១៥**

**ម៉ោង 6:30 ល្ងាចរហូតដល់កណ្ដាលយប់**

**ភោជនីយដ្ឋាន ប៉ៃលិន**



2015 Guest Speaker
Judge Meng H. Lim
Tallapoosa, GA

សូមអញ្ជើញចូលរួមក្នុងរាត្រីសមោសរដែលមានពិធីសម្តែងសិល្បៈចម្រុះវប្បធម៌មានវាគ្មិនពិសេសទទួលទានអាហារដោយមានតន្ត្រីប្រគុំកំដរ និងរាំកំសាន្តរហូតកណ្តាលរាត្រី។ ដូចឆ្នាំមុនដែរ ឆ្នាំនេះយើងបានអញ្ជើញវាគ្មិន ពិសេសគឺលោកចៅក្រម លឹម ម៉េង ជាចៅក្រមខ្មែរអាមេរិកតុលាការកំពូលនៃរដ្ឋ Georgia។





**តម្លៃសំបុត្រ៖ ៣៥ដុល្លា (ទិញមុន) / ៤០ដុល្លា (ទិញថ្ងៃរាត្រីសមោសរ)**

**កក់កន្លែងមុន៖ សូមទាក់ទង ពិន សុបិន្ត តាមរយៈទូរស័ព្ទ 978-656-8141**

Tickets : $35 Advance Purchased | $40 Paid at Door

Contact: Soben Pin 978-656-8141 (Cell) | 978-677-7163 (Office)

Sponsorship Info:www.khmerpost.us/gala-2015

# ការបោះឆ្នោតនៅវត្តត្រៃរតនារាម

ដោយ ខ្មែរប៉ុស្ដិ៍ស.រ.អា

**ឡូវែល:** ការបោះឆ្នោតដែលគណកម្មការវត្តលើជឿថា ធ្វើឡើងដើម្បីបញ្ចប់អធិករណ៍នៅវត្តត្រៃរតនារាមបានប្រព្រឹត្តចប់សព្វគ្រប់នៅវេលាម៉ោង៣ រសៀល ថ្ងៃអាទិត្យ ទី២៩ ខែមីនា ឆ្នាំ ២០១៥ នៅក្នុងវិហារជាន់លើនៃវត្តត្រៃរតនារាម។ ជាលទ្ធផលលោក អ៊ិរិន ធីម ទទួលបានសម្លេងគាំទ្រលើសលុប និងបានជាប់ឆ្នោតជាប្រធានគណកម្មការវត្តជំនួសប្រធានចាស់។ ចំនួនអ្នកបោះឆ្នោតសរុបមាន៣៥៣នាក់។ បេក្ខជនឈរឈ្មោះបោះឆ្នោតមានចំនួន៥រូប ដែលមានរាយនាមដូចខាងក្រោម:

១-លោក អ៊ិរិន ធីម ទទួលបាន ២៣៧សម្លេង
២- លោក ផុន្នី ឆេង ទទួលបាន៤២សម្លេង
៣- លោក ប៉ាហ៊ិម កែ ទទួលបាន៣១សម្លេង
៤- លោក ចិន្ដា ប្រាក់ ទទួលបាន២៩សម្លេង
៥- អ្នកស្រី លក្ខិណា អ៊ុក ទទួលបាន១៧សម្លេង

បន្ទាប់ពីប្រកាសលទ្ធផលបោះឆ្នោតលោក ចននី បានមានប្រសាសន៍ថា "ការបោះឆ្នោតនេះធ្វើស្របទៅតាមសេចក្ដីសម្រេចរបស់តុលាការកំពូលនៅរដ្ឋម៉ាស្សាឈូសេតដែលអនុញ្ញាតឱ្យយើងធ្វើ។ បើតាមច្បាប់By-Lawរបស់វត្តដប់ថ្ងៃបន្ទាប់ពីនេះ យើងនឹងបញ្ជូនសមាភាពគណកម្មាធិការថ្មីទៅ Secretary of State ដើម្បីឱ្យគេទទួលស្គាល់"។ លោក ចននី បានប្រកាសបន្តថា "យើងនឹងជម្រាបដំណឹងនេះ ទៅខាងនាយកដ្ឋានប៉ូលិស និងនាយកដ្ឋានអគ្គីភ័យក្រុងឡូវែលផងដែរ។ ដូច្នេះដប់ថ្ងៃក្រោយការបោះឆ្នោត គណកម្មាធិការថ្មីនេះ នឹងមានភាពស្របច្បាប់ តាមការអនុញ្ញាតរបស់តុលាការ។ នៅទីបញ្ចប់វត្តយើងមានសន្តិភាព និងជាវត្តតែមួយ"។

លោក អ៊ិរិន ធីម ដែលបានជាប់ឆ្នោតថ្មីមានការរំភើបចិត្តយ៉ាងខ្លាំង។ លោកបានមានប្រសាសន៍ថា "ខ្ញុំសប្បាយចិត្តណាស់ ដែលបានជាប់ឆ្នោតនៅថ្ងៃនេះ។ ខ្ញុំនឹងរៀបចំវត្តយើងឱ្យមានស្ថេរភាពល្អ និងបញ្ចប់ជម្លោះដែលកើតមានជិតម្ភៃឆ្នាំកន្លងមក។ ខ្ញុំនឹងសុំឱ្យគណកម្មការខ្ញុំមួយចំនួនឱ្យជួយកិច្ចការខ្ញុំ។ ខ្ញុំនឹងសុំបង ចិន្ដា ប្រាក់ ជាអនុប្រធានទី១ បងអាចារ្យក្មេង ផុន្នី ឆេង ជាអនុប្រធានទី២"។ លោកអ៊ិរិនបន្តទៀត ថា "ខ្ញុំសុំលោកពូ ប៉ាហ៊ិម កែ ឱ្យនៅបន្តជាចាស់ព្រឹទ្ធាចារ្យជួយផ្ដល់ប្រឹក្សាយោបល់ដល់ខ្ញុំ។ នេះភ័ព្វព្រេងវាសនាសម្រាប់ឧបាសកឧបាសិកាដែលប្រាថ្នាចង់យកធាតុមកតម្កល់ក្នុងវត្តនេះ **តទៅទំព័រទី ២៥**




បេក្ខជន៥រូបឈ្មោះតាមលេខរៀង


ព្រះសង្ឃបើកសន្លឹកឆ្នោត

MIDDLESEX
Community College
BEDFORD · LOWELL

BEDFORD OPEN HOUSE

Thursday, April 28 ▪ 5:30 p.m.

591 Springs Road ▪ Bedford, MA 01730

Learn more about ...

FREE Tutoring Services ▪ Placement Testing ▪ Dual Enrollment ▪ Disability Support ▪ Academic, Career & Transfer Counseling

Middlesex offers 75+ degree & certificate programs, and hundreds of noncredit courses. Earn a degree, begin a bachelor's degree or upgrade your skills.







Everyone teaches, everyone learns.

REGISTER NOW!

To learn more or to RSVP call 1-800-818-3434 or visit: www.middlesex.mass.edu/OH

# បុណ្យអ៊ីស្ទើរ

**ដោយ រីឆាត ហូវ ជូនៀ**
**ប្រែសម្រួលដោយៈ ថាច់ វណ្ណា**

បុណ្យអ៊ីសស្ទើរជាបុណ្យធ្វើទៅតាមសាសនាគ្រីស្ត ដើម្បីរំលឹកថ្ងៃព្រះយេស៊ូស្លាប់ហើយរស់ឡើងវិញ. យោងតាមគម្ពីរបាយបឺល(bible) បានចែងថាៈ ព្រះយេស៊ូជាកូនប្រុសរបស់ព្រះអាទិទេព. បានកើតមកជាមនុស្សប្រុសម្នាក់. ពេលយេស៊ូមានអាយុ៣០ឆ្នាំ. ការប្រៀនប្រដៅរបស់យេស៊ូធ្វើឱ្យមានការគម្រាមដល់សាសនាដទៃ និងអ្នកកាប់អំណាចនយោបាយ ។ ម្លោះហើយពួកគេក៏រួមគំនិតគ្នារៀបគំរោងការដើម្បីសម្លាប់គាត់ ។ នៅរាត្រីមុនពេលគាត់ស្លាប់, គឺជាយប់ថ្ងៃសុក្រជាថ្ងៃរៀបចំពិធីបុណ្យសាសនា ជ្វីហ្វ (Jewish) យេស៊ូ បានទទួលទានពេលល្ងាចរួមជាមួយ និងក្រុមអ្នកជិតស្និទ្ធរបស់គាត់ ។ ពេលទទួលទាននេះក៏បានក្លាយទៅជាការទទួលទានពេលល្ងាចចុងក្រោយបំផុតរបស់គាត់. យេស៊ូបានចែកនំប៉ុង និងស្រាដល់មិត្តភ័ក្តិរាល់គ្នា.ការចែករំលែកនេះបានក្លាយទៅជាមូលដ្ឋានគ្រឹះក្នុងចំណោមមហាជននៃសាសនាកាតូលិក ។

បន្ទាប់ពីរាត្រីនោះ,យេស៊ូត្រូវបានគេចាប់ខ្លួន. **តទៅទំព័រទី ១០**



# Easter

**By Richard P. Howe Jr.**

Easter is a Christian religious holiday that celebrates the resurrection of Jesus Christ from the dead. According to the bible, Jesus was the son of God and was born as a man. By the time Jesus was 30 years old, his teaching became a threat to those who held religious and political power so they conspired to kill him. The night before his death which would occur on the Friday of the Jewish celebration of Passover, Jesus ate dinner with his closest followers. During this meal, which became known as the Last Supper, Jesus shared bread and wine with his friends. This sharing became the basis of the mass in the Catholic religion.

Later that night, Jesus was arrested. The next day, Jesus was executed by being nailed to a large wooden cross. Once he died, his friends buried him in a cave and blocked the opening with a large boulder. On Sunday when the friends returned to the grave, they found the boulder had been moved and the body of Jesus was gone. He later appeared to his followers, proving that he had risen from the dead and that he was the Son of God as was described in the Bible.

The day Jesus died is known as Good Friday and the day he rose from the dead became Easter Sunday. Easter falls on a different day each year. It is always the first Sunday after the first full moon that comes on or after March 21. This year, Easter falls on April 5 (although the Eastern Orthodox Church celebrates it a week later due to differences in the church calendars).

There are also non-religious traditions connected with Easter. They are mostly based on centuries-old German traditions that were a way of celebrating the end of winter and the arrival of spring. For example, German people believed that the night before Easter, a magical rabbit would come to the homes of children who were well-behaved during the year and would leave them candy and gifts from a basket he carried. This is the origin of the Easter bunny and Easter basket symbols. At the same time, religious rules forbade people from eating eggs during the weeks before Easter so people would boil the eggs to preserve them until Easter when they could be eaten. This is the origin of the Easter egg symbol. The traditional meal on Easter Sunday is ham. This is because before refrigeration, ham could be stored for long periods of time so it was the only meat available in the spring after a long winter.

Easter is the holiest day of the year in the Christian religion, but it also shares the practice of celebrating the end of winter and the arrival of spring with other religions and cultures.



....លិខិតអ្នកអាន....

# សំណើរឱ្យលុបកិច្ចព្រមព្រៀង"ក្រុងបងប្អូន" ជាមួយរដ្ឋាភិបាលខ្មែរ

សមាជិកសហគមន៍ខ្មែរឡូវែល៩រូប បានផ្ញើរលិខិតមួយសំដែងការមិនពេញចិត្តរួមគ្នា ចំពោះលោកអភិបាលក្រុងឡូវែលដែលបានចុះហត្ថលេខាជាមួយអភិបាលក្រុងភ្នំពេញ កាលពីថ្ងៃ ១៥មករា ឆ្នាំ២០១៥ ព្រមព្រៀងគ្នាដាក់ក្រុងភ្នំពេញនឹងក្រុងឡូវែលជាបងប្អូននឹងគ្នា ។ លិខិតនោះសរសេរមានន័យដោយសង្ខេបថា "ប្រជាពលរដ្ឋដែលរស់នៅឡូវែលសុទ្ធតែបានគេចចេញពីរបបកុម្មុយនីស្តតាំងតែពីជាង៣០ឆ្នាំមកហើយ" ពួកគាត់ដឹងថា "ការគ្រប់គ្រងប្រទេសកម្ពុជាសព្វថ្ងៃនេះ ក៏នៅក្នុងកណ្តាប់ដៃជនផ្តាច់ការនិយម ហ៊ុន សែន ជារៀងរហូតមកធ្វើប្រទេសខ្មែរនៅសល់តែអំពើពុករលួយគ្រួសារនិយមគម្រាមកំហែងធ្វើបាបប្រើហឹង្សាលើពលរដ្ឋខ្លួនឯងត្រួតត្រាលើស្ថាប័នជាតិទាំងអស់"។ នៅពេលចងស្ពានមេត្រីជាមួយឡូវែលលោក ហ៊ុន សែន ចង់បានឱ្យពិភពលោកមើលឃើញថា ខ្លួនធ្វើបានល្អ ហើយប្រាកដជាយកឡូវែលជាអាវុធប្រឆាំងនឹងពលរដ្ឋក្រីក្រខ្មែរតទៅទៀត។

ហេតុនេះហើយបានជាយើងសូមឱ្យ"លោកអភិបាលក្រុងពិចារណាឡើងវិញ ហើយលុបកិច្ចព្រមព្រៀងជាមួយភ្នំពេញនោះចោលចេញ ។

ហត្ថលេខាអ្នកទាំង៩នាក់លក្ខណៈជាថ្នាក់ដឹកនាំសហគមន៍មាន : ម៉ទីណល់ ចាន់- ចិន្តា គ្រុឌ - ធីម៉ធី មុត - បុផ្ផា ពៅ - ថាវា រស់ - ស ផៃល - កេតូ តាន់ - ឆាន ទូច -វត្ថានា វ៉ែន ។




សូមអានអត្ថបទដែលបានផ្ញើរទៅជូនអភិបាលក្រុង អេលីយ៉ត រ៉ទនី ប្រធានសាលាក្រុង ខេវិន ម័រហ្វីនឹងគណក្រុមប្រឹក្សាភិបាលក្រុងខាងក្រោមនេះ។

# Request to Nullify Sister-City

March 25, 2015
The Honorable Rodney M. Elliott
Mayor
375 Merrimack Street
2nd Floor, Room 50
Lowell, MA 01852

Dear Mayor Elliott:

**Subject: Request to Nullify Sister-City with Cambodian Government**

The purpose of this letter is to voice our disappointment with you and your colleagues regarding the Lowell - Phnom Penh sister-city agreement that was signed in the Cambodian capital on January 15, 2015. As City of Lowell residents, who have escaped from and are aware of prime minister Hun Sen's government, we believe Lowell is doing democracy a grave disservice by having ties with this regime. Mr. Hun Sen is running Cambodia as a functional equivalent to a dictatorship, exemplified by many years of abuse of power.

At least one-third of Lowell's residents were immigrants who escaped communism or dictatorship run governments. Among them, Cambodian-Americans stand out the most. While Mr. Hun Sen and his supporters might have claimed that Cambodia is a democratic country, the former Khmer Rouge's member has ruled Cambodia for 30 years. Under his reign, Cambodia relies heavily on international aid and most Cambodian people are still struggling to make ends meet. Corruption, impunity, nepotism, eviction, and violence have plagued the nation while the prime minister's family and his cronies act as though they are above the law, and have become extremely wealthy through the years.

In addition to having a complete control over the Executive, Legislative and Judicial branches of government, Mr. Hun Sen commands very loyalist bodguards that **Continued to page 24**




SFS THE SCHOOL FOR FIELD STUDIES
www.fieldstudies.org ☎ 800-989-4418
sfs@fieldstudies.org Find us on Facebook

**Scholarships for Cambodian-American Students!**

"The Living Mekong" program, based in Siem Reap, is a semester-length environmental study abroad program for undergraduate students. This unique field-based academic program examines the importance of the Mekong River as a source of livelihood for millions of people. **Now accepting applications.**

# “កុំស្មានបងភ្លេច” ខ្មែរបាត់បង់តន្ត្រីរ៉ក់

**ដោយ ស្ដាយ បុណ្យ**

"...ស្ដាយភូមិកំណើត ស្ដាយអនុស្សា ស្ដាយញាតិកា ធ្លាប់រស់សុខសាន្ដ
ស្ដាយដូរតន្ត្រីដ៏សែនមនោរម្យ ខ្លួនខ្ញុំឃ្លាតឆ្ងាយ ឆ្ងាយដាច់អាល័យ ។
ស្ដាយអ្នកចម្រៀងដែលបង់បាត់ ស៊ីន ស៊ីសាមុត រស់ សេរីសុទ្ធា
ប៉ែន រ៉ន សុះ ម៉ាត់ អ៊ិន យ៉េង អ៊ឹង ណារី ក្លាយជាធុលីលាចាកលោកា..."

ខាងលើនេះ គឺជាទំនុកច្រៀង ក្នុងបទចម្រៀង "ស្ដាយភូមិកំណើត" របស់លោក កែវ សារ៉ាត់។ លោកបានរៀបរាប់អំពីអ្នកចម្រៀងដែលបានបាត់បង់ជីវិតក្នុង



ក្រុមតន្ត្រីបក្សីចាំក្រុង១៩៦៨






អ្នកស្រី សៀង ឌី ១៩៦៥

របប ប៉ុល ពត ។ ជាអកុសល លោក កែវ សារ៉ាត់ ខ្លួនឯងក៏បានលាចាកលោកបាត់ទៅហើយដែរ ។ ទោះបីគាត់ស្លាប់នៅក្រោយរបបខ្មែរក្រហមក្ដី ក៏មានអ្នកចម្រៀង និងតន្ត្រីករខ្មែរតិចតួចណាស់ ដែលរស់រួចផុតរបបវាលពិឃាតនេះ ។

តន្ត្រីរ៉ុក និងតន្ត្រីសម័យរបស់ខ្មែរមានភាពល្បីរន្ទឺខ្លាំងក្នុងទសវត្សមុនសង្គ្រាមឆ្នាំ១៩៧០ ។ ទំនុកច្រៀង និងទំនុកភ្លេងនៃបទពីដើមសុទ្ធតែបង្កប់ទឹកដម និងអត្ថន័យជ្រាលជ្រៅ លួងលោម បំពេរអារម្មណ៍អ្នកស្ដាប់ឱ្យស្ទុងចិត្តនឹកគិតឃើញដល់រូបភាពក្នុងរូបារម្មណ៍ ហាក់ដូចស្ទែងនូវទិដ្ឋភាពពិតនៅនឹងមុខ ។ ទឹកដៃនិពន្ធបទភ្លេង និងទំនុកច្រៀងរបស់រៀមច្បងសិល្បៈករជំនាន់ដើមធ្វើឱ្យបទភ្លេង និងចម្រៀងរបស់ពួកគាត់នៅរស់រានមានជីវិតទោះបីម្ចាស់បទបានស្លាប់ចោលបទបាត់ទៅហើយក្ដី ។

ក្នុងចំណោមអ្នកចម្រៀង និងយុវតន្ត្រីករដ៏ល្បីបំផុតជំនាន់ទសវត្សឆ្នាំ១៩៦០ និង១៩៧០ដែលនៅរស់រានមាន

តទៅទំព័រទី ១២

# Lowell Celebrates Cambodia's Lost Rock and Roll eras

**By Suzzanne Cromwell**

GROUNDBREAKING DOCUMENTARY TRACING CAMBODIA'S 50s, 60s and 70s ICONIC ROCK AND ROLL MOVEMENT COMES TO LOWELL!

"Don't Think I've Forgotten: Cambodia's Lost Rock and Roll" Film and Live Concert Tour Includes the Official Lowell Premiere on April 24th with a Special LIVE Musical Concert on April 26th with Cambodian Artists Featured in the Film

Through the eyes, words, and songs

**Continued to Page 12**



# បទសម្ភាសន៍ជាមួយលោក កឹម សុខា អនុប្រធានទី១នៃរដ្ឋសភាជាតិ

**ដោយ ពិន សំខុន**

*គណបក្សសង្គ្រោះជាតិនៅឡូវែលបានរៀបចំទទួលភ្ញៀវកិត្តិយសរបស់ខ្លួន-លោក កឹម សុខា អនុប្រធានបក្ស កាលពីថ្ងៃទី២១មិនា២០១៥។ នៅគេហដ្ឋានឡូវែលលោក ង៉ោ គិមឈៀង សមាជិកសភាខ្មែរដែរនោះលោក កឹម សុខា បានផ្តល់កិច្ចសម្ភាសន៍ឱ្យខ្មែរផុសស.រ.អា. ដូចតទៅ :*


លោក កឹម សុខា
ពិន សំខុន

**សួរ:** ជម្រាបសួរឯកឧត្តម កឹម សុខា! តើទស្សនកិច្ចរបស់ឯកឧត្តមតាំងតែពីមកដល់សហរដ្ឋអាមេរិកបានអញ្ជើញទៅទីណាខ្លះហើយ ?

**កឹម សុខា:** ជម្រាបសួរលោក ពិន សំខុន! ខ្ញុំបានមកដល់សហរដ្ឋអាមេរិកនេះថ្ងៃ១៤មីនា ចុះនៅកាលីហ្វ័រញ៉ាជួបបងប្អូនខ្មែរយើងនៅខាងជើងផងនៅខាងត្បូងផង ថ្ងៃ១៥-១៦ទៅតាកូមា ថ្ងៃ១៧ទៅដល់តិនីស៊ី ថ្ងៃ១៨ នៅវ៉ាស៊ីនតុនឌីស៊ី ថ្ងៃ១៩ជួបបងប្អូននៅហ្វីឡាដែលហ្វៀ ថ្ងៃ២០-២១ បានមកដល់ឡូវែលនេះ ថ្ងៃ២២នឹងទៅដល់តិចសាស់ទៀត...

**សួរ:** បញ្ហាដែលខ្ញុំចង់ដឹងថ្ងៃនេះ ថាតើច្បាប់បង្កើតគណកម្មការរៀបចំការបោះឆ្នោត គឺ គ.ជ.ប. ដែលទើបនឹងអនុម័ទតើគណបក្សសង្គ្រោះជាតិយល់ថា ជាជោគជ័យ ឬក៏បរាជ័យ?

**កឹម សុខា:** គណបក្សសង្គ្រោះជាតិនឹងគណបក្សប្រជាជនបានបើកការចរចាគ្នាអស់រយៈពេលជិតកន្លះឆ្នាំ ទើបតែសភាអនុម័តកាលពីថ្ងៃ១៩មុននេះ លទ្ធផលមិនបានជាជោគជ័យទាំងស្រុងទេ មានចំណុចខ្វះខាតជាច្រើនហើយសង្គមស៊ីវិលបង្ហាញថា មិនពេញចិត្តច្រើន... ដែលយើងគួរយល់នោះ គឺនៅពេលចរចាគ្នាមានចំណុចជាច្រើនដែលយើងមិនពេញចិត្តពីព្រោះយើងចង់ឱ្យបានច្បាប់មួយដែលប្រសើរដូចដែលសង្គមស៊ីវិលចង់បានដូច្នោះដែរ ក៏ប៉ុន្តែខាងគណបក្សប្រជាជនឯណោះក៏គេមានការមិនពេញចិត្តចំណុចយើងច្រើនដែរ ដែលក្នុងកិច្ចចរចានីមួយៗតែងតែមានថយក្រោយមួយក៏រិតម្នាក់តែចំណុចដែលយើងយល់ថា ប្រសើរជាងមុននោះនៅត្រង់ ១-គ.ជ.ប. មានតុល្យភាពជាងមុនដោយគណបក្សទាំងពីរមានតំណាង៤នាក់ស្មើរគ្នា បូកនឹងសមាជិកឯករាជ្យម្នាក់ដែលរូបភាពនេះត្រូវរៀបចំថ្នាក់ខេត្តក្រុងបន្ទាប់មកទៅតាមស្រុកសង្កាត់ជាច្រើនពាន់នាក់ថែមទៀត ២-រៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតសារជាថ្មីដែលរាល់ដងបាត់ឈ្មោះប្រមាណជា១លាននាក់ដែលច្រើនជាឈ្មោះអ្នកប្រឆាំង ទើបបានជាបាត់។

**សួរ:** ប្រជាពលរដ្ឋកាលពីចុងឆ្នាំ២០១៣ បានចេញមកច្រើនណាស់ប្រឈមមុខនឹងគ្រោះថ្នាក់ ដើម្បីគាំទ្រសង្គ្រោះជាតិបើច្បាប់បង្កើតគ.ជ.ប.បានត្រូវគេបន្ទោសច្រើនយ៉ាងហ្នឹង តើនេះមិនមែនជាការធ្វើការដោយគិតស្រាលពេកទេដឹង?

**កឹម សុខា:** យើងចរចាអស់កន្លះឆ្នាំដោយត្រូវគេគម្រាមផង គេចាប់ពួកយើងដាក់គុកផង នេះមិនមែនជាការគិតស្រាលទេគឺជាការតស៊ូខ្លាំងណាស់ដែលយើងគួរតែទទួលការកោតសសើរដូចខ្ញុំបាននិយាយអម្បាញ់មិញនេះហើយថាយើងចងបានច្បាប់មួយដ៏ល្អតែគណបក្សប្រជាជនគេដាក់ការយល់ទាស់ដ៏ច្រើនតាំងពីកំរិតក្រុមចរចាដល់ថ្នាក់កំពូលយើងដោះបានចំណុចធំៗ ដែលយើងចង់បាន ហើយតែនៅកិច្ចចរចា គឺទាល់តែយើងថយម្នាក់មួយជំហានទើបយើងបានសម្រេចផលតែត្រឹមនេះសង្គមស៊ីវិលគេបន្ទោសនោះមិនខុសទេ ។

**សួរ:** បើសង្គ្រោះជាតិតស៊ូក្រុមសង្គមស៊ីវិលតស៊ូហើយលោក ហ៊ុន សែន មើលឃើញថាឯកឧត្តមប្រាថ្នាផ្តួលរំលំរដ្ឋាភិបាលខ្ញុំគិតថា គណបក្សណាក៏ដោយក៏ចង់ផ្តួលរំលំគូរបដិបក្ខរបស់ខ្លួនដែរ តើក្រៅពីការគម្រាមកំហែងតើលោក ហ៊ុន សែន នៅមានអ្វីត្រូវធ្វើទៀតទេ?

**កឹម សុខា:** យើងមិនដែលចង់ឈ្នះដោយអំពើហឹង្សាម្តងណាទេទោះជាគិតក៏មិនដែលគិតផងយើងចង់ឱ្យមានការផ្លាស់ប្តូរមែនតែយើងប្រើមធ្យោបាយអហឹង្សានេះជាការលំបាកដែលយើងមានការប្រថុយប្រថានខ្លាំងណាស់ ប្រឈមនឹងការគម្រាមកំហែងដែលគេប្រើមកលើយើងរាល់ពេលគេអាចប្រើអំណាចប្រើតុលាការបានទាំងអស់ដែលនេះសុទ្ធតែជាការបំពានចំណែកយើងបើចង់ប្រើហឹង្សាក៏ធ្វើមិនកើតដែរ ហើយក៏ចង់ចៀសផង ពីព្រោះតែធ្វើវាស្លាប់ជាតិវាស្លាប់ខ្មែរតែហេតុអ្វីបានជាយើងប្រថុយ? វាទាល់តែយើងហ៊ានប្រថុយនោះហើយទើបមានការផ្លាស់ប្តូរនេះ ហើយជាគោលការណ៍នឹងបុព្វហេតុរបស់យើងដែលត្រូវការឱ្យមានការផ្លាស់ប្តូរជូនប្រជាពលរដ្ឋ។

**សួរ:** ខ្ញុំសង្កេតឃើញថា ក្នុងពេលអនុមតិច្បាប់បង្កើតគ.ជ.ប.ថ្មីឯកឧត្តមឥតបាននៅបោះឆ្នោតជាមួយសមាជិកសភាទាំង១០៤នាក់នោះទេ តើហេតុអ្វី?

**កឹម សុខា:** ខ្ញុំមានគម្រោងរួចហើយថា ត្រូវចេញធ្វើដំណើរ **តទៅទំព័រទី១១**


B&M
DISPOSAL
ក្រុមហ៊ុនដឹកជញ្ជូនសំរាម ប៊ីអឹម



កុងទីន័រដាក់សម្រាម 30 YARD CONTAINER
រហូតដល់ ៤ តោន $549
កុងទីន័រដាក់សម្រាម 20 YARD CONTAINER
រហូតដល់ ៣ តោន $449
កុងទីន័រដាក់សម្រាម 15 YARD CONTAINER
រហូតដល់ ២ តោន $349

*សូមបង់ថែម $100 ក្នុង ១០០០ ផោនបន្ថែម ។ អនុញ្ញាតឱ្យដាក់បន្ថែមលើសទម្ងន់អតិបរមានៅលើកុងទីន័រណាមួយខាងលើបាន ។

សូមទាក់ទងឈ្មោះ ប៊ុន ឥឡូវនេះ!
មានផ្តល់សេវាជូនដល់ហាងទំនិញ និងតាមផ្ទះ




BUSINESS – RESIDENTIAL
*CAll BUN NOW ! 978-569-6062*



LEGEND
AUTO BODY INC.
(978) 458-2085

**Services**
- Auto Body
- Auto Mechanics
- Foreign and Domestics
- State and Insurance Certified

Towing - **978-815-9957** (K.C)

**មានបម្រើ**
- ជួសម៉ាស៊ីនយានយន្ត
- ប្រភេទយានយន្តក្នុង និងក្រៅប្រទេស

**ក្តូយានយន្ត**
- បញ្ជាក់បណ្ណធានារ៉ាប់រងទទួលស្គាល់ដោយរដ្ឋ

**ដឹកឡានត្រូវចជូវ** 978-815-9957 (ខេ-ស៊ី)



115 Rock St. Unt #7 Lowell, MA 01854

# អំពីទីក្រុងនៅតំបន់ Greater Merrimack Valley

**ដោយ Deb Belanger**

**ប្រែសម្រួលដោយ មួង ណារ៉េត**

សូមអញ្ជើញចូលរួមអបអរ**ទិវាអ្នកស្នេហាជាតិ(Patriots Day)** នាចុងសប្តាហ៍ (ថ្ងៃទី ១៨, ១៩,២០ ខែ មេសា) ប្រារព្ធធ្វើលើទឹកដីនៃសេរីភាពដំបូង!

នៅពាក់កណ្តាលខែ មេសា មានមនុស្សរាប់ពាន់នាក់ធ្វើដំណើរទៅតំបន់ Lexington និង Concord ដែលជាកន្លែងប្រវត្តិសាស្ត្រ ដើម្បីអបអរទិវាអ្នកស្នេហាជាតិ។ ទិវាអ្នកស្នេហាជាតិជាថ្ងៃបុណ្យជាតិពិសេសមួយរបស់រដ្ឋម៉ាស្សាឈូសេត។ គេប្រារព្ធទិវានេះ ដើម្បីរម្លឹកដល់ការចាប់ផ្តើមសមរភូមិសង្គ្រាមបដិវត្តអាមេរិកនៅខែមេសា ឆ្នាំ១៧៧៥។ ពេលនោះឯងដែលជាពេលចាប់ផ្តើមដំបូងនៃការទទួលបានសេរីភាពមកជូនប្រទេសជាតិរបស់យើង ។ បុណ្យជាតិឆ្នាំនេះនឹងប្រារព្ធធ្វើនៅថ្ងៃ ចន្ទ ទី ២០ ខែ មេសា ឆ្នាំ ២០១៥។ ប៉ុន្តែយើងនឹងអបអរទិវានេះពេញមួយសប្តាហ៍។ ដំណើរព្យុហយាត្រាការសម្តែងឡើងវិញដើម្បីរម្លឹកព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ និងពិធីរម្លឹកអនុស្សាវរីយ៍នឹងប្រព្រឹត្តទៅនៅទីកន្លែងផ្សេងៗគ្នានៅតំបន់ Lexington និង Concord។ ពិធីនឹងមានរៀបចំធ្វើនៅសួនសាធារណៈ Minuteman National Park ផងដែរ។

ព្រឹត្តិការណ៍សំខាន់ៗ ដែលមិនត្រូវរំលង រួមមាន :

ថ្ងៃ អាទិត្យ ទី ១៩ ខែ មេសា វេលាម៉ោង៦ព្រឹក

Dawn Salute

North Bridge, Concord

**កងឈ្លបវាយរហ័ស ឬហៅថា the Concord Minute Men និងក្រុមកងកាំភ្លើងធំស្វយ័ត** និងប្រារព្ធពិធីបើកសមរភូមិបដិវត្តអាមេរិកដោយការបាញ់កាំភ្លើងវែង២១ដើម និងកាំភ្លើងធំ ដើម្បីសម្តែងការគោរព។

ថ្ងៃទីអាទិត្យ ទី ១៩ ខែ មេសា វេលាម៉ោង ៧ និង ៣០ នាទីព្រឹក និង ម៉ោង ១០ ព្រឹក

"កងទ័ពអាមេរិក" បង្ហាញទាហានពីកងវរសេនាតូចក្នុងកងថ្មើរជើងទី៣ នៃកងវរសេនាធំអាមេរិក ឬហៅថា the Old Guard។

North Bridge, Concord

កងថ្មើរជើងទី៣ របស់អាមេរិក ឬហៅថា the Old Guard ជាកងថ្មើរជើងដែលនៅសកម្មយូរជាងគេនៅក្នុងកងទ័ពអាមេរិក។ កងថ្មើរជើងនេះ បង្កើតដំបូងតាំងពីជំនាន់សង្គ្រាមបដិវត្ត



និងនៅបន្តមានវត្តមានដល់ពេលបច្ចុប្បន្ន។ ក្រុមនេះ មានបទភ្លេងទ័ព និងនិទានកថាដែលជាមោទនភាពសម្តែងអំពីភាពជាអ្នកស្នេហាជាតិដែលជម្រុញកម្លាំងវីរភាពក្នុងពេលធ្វើសឹកសង្គ្រាម។ ទាំងនេះនឹងមានបង្ហាញជូននៅក្នុងទិវាអ្នកស្នេហាជាតិ។

ថ្ងៃទី ចន្ទ ទី ២០ ខែ មេសា វេលាម៉ោង ៥ និង ៣០ នាទីព្រឹក ។

ការសម្តែងឡើងវិញនូវព្រឹត្តិការណ៍ក្នុងសមរភូមិនៅ Lexington

Lexington Green

ក្រុង Lexington អបអរពិធីចាប់ផ្តើមនៃបដិវត្តដំបូង ដោយការសម្តែងឡើងវិញនូវព្រឹត្តិការណ៍ប្រយុទ្ធគ្នាដែលកើតឡើងនៅព្រឹកព្រលឹមស្រាងៗ រវាងកងឈ្លបក្រុង និងកងទ័ពស្រួចអង់គ្លេស។

ថ្ងៃទីចន្ទ ទី ២០ ខែ មេសា វេលាម៉ោង ៨ និង៤៥ នាទីព្រឹក

**តទៅទំព័រទី២៨**

adventures await

Greater Merrimack Valley
Convention & Visitors Bureau

For more fun things **to see & do** and great places **to eat & stay**, visit...
www.merrimackvalley.org

# About Town in the Greater Merrimack Valley

**By Deb Belanger**

Come Celebrate **Patriots Day weekend** (April 18,19, 20) with us in the region where freedom began!

In mid-April, thousands of people travel to historic Lexington and Concord to celebrate Patriot's Day. Patriot's Day is a special Massachusetts State holiday commemorating the opening battle of the American Revolutionary War, April 19, 1775 which brought freedom to our nation. This years' holiday will officially be observed on Monday, April 20, 2015 however, there is an entire week to be celebrated with parades, reenactments and commemorative ceremonies at various sites throughout Lexington and Concord, including the Minuteman National Park.

A few highlights not to be missed, include:

Sunday, April 19th, 6:00 a.m.

Dawn Salute

North Bridge, Concord

The **Concord Minute Men and the Concord Independent Battery** observe the opening battle of the American Revolution with a 21 gun musket and cannon salute.

Sunday, April 19th, 7:30 and 10:00 a.m.

"America's Army" featuring soldiers from the 4th Battalion of the 3rd U.S. Infantry Regiment -The Old Guard

**North Bridge, Concord**

The 3rd U.S. Infantry, known as The Old Guard,

**Continued to page 28**



# លោក ហង្ស ពុទ្ធា អ្នកសង្កេតការណ៍បោះឆ្នោតដ៏លេចធ្លោម្នាក់ ត្រូវបានតែងតាំងជាសមាជិក "អព្យាក្រឹត"ថ្មីរបស់ គ.ជ.ប.

ដោយ គុជ ណារ៉េន និង អេឡិក វិល្លឹមមីនស៍

| April 1, 2015

កាលពីម្សិលមិញលោក ហង្ស ពុទ្ធា នាយកប្រតិបត្តិនៃគណៈកម្មាធិការអព្យាក្រឹត និងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា ហៅកាត់ថា និចហ្វិច ត្រូវបានជ្រើសរើសជាបេក្ខជនសមាជិក "អព្យាក្រឹត" នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប.) ក្រោយពីលោកស្រី ពុង ឈីវកេក ប្រធានអង្គការសិទ្ធិមនុស្សលីកាដូ បានច្រានចោលការតែងតាំងលោកស្រី។

ការចរចារយៈពេល៧ខែបានឈានទៅដល់ការអនុម័តច្បាប់ថ្មីចំនួនពីរកាលពីសប្ដាហ៍មុន ដោយត្រួសត្រាយផ្លូវសម្រាប់បង្កើតគ.ជ.ប.ថ្មី ដែលមានបេក្ខជនបួនរូបមកពីគណបក្សប្រជាជនកម្ពុជាកំពុងកាន់អំណាច និងបួនរូបមកពីគណបក្សសង្គ្រោះជាតិ ព្រមទាំងសមាជិកមួយរូបចុងក្រោយដែលគណបក្សទាំងពីរអាចទទួលយកបាន។

លោកស្រី ពុង ឈីវកេក បានទទួលយកតំណែងជាសមាជិក "អព្យាក្រឹត" របស់ គ.ជ.ប. នេះកាលពីឆ្នាំមុន ប៉ុន្តែកាលពីម្សិលមិញ លោកស្រីបានចេញសេចក្តីថ្លែងការណ៍មួយកែប្រែការសម្រេចចិត្តរបស់លោកស្រីដោយមានប្រសាសន៍ថា មុខតំណែងនៅក្នុងគ.ជ.ប.នេះ នឹងមិនអាចធានាបាននូវភាពឯករាជ្យដូចដែលបានសន្យានៅពេលលោកស្រីទទួលតំណែងនេះឡើយ។

កាលពីល្ងាចម្សិលមិញគណបក្សប្រជាជនកម្ពុជាបានផ្សព្វផ្សាយលិខិតមួយច្បាប់ចុះថ្ងៃអាទិត្យ ដែលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ផ្ញើជូនលោក សម រង្ស៊ី ប្រធានគណបក្សប្រឆាំង ដោយបញ្ជាក់ថា លោក ហង្ស ពុទ្ធា គឺជាអ្នកដែលត្រូវជំនួស

តទៅទំព័រទី ២៣



# NGO Director Appointed New 'Neutral' NEC Member

By Alex Willemyns and KuchNaren

| April 1, 2015

Hang Puthea, executive director of the Neutral and Impartial Committee for Free and Fair Elections, was selected Tuesday as the "neutral" candidate for the National Election Committee (NEC) following Licadho president PungChhivKek's announcement that she would not accept her nomination.

Seven months of negotiations led to the adoption last week of two new laws paving the way for the new NEC, which will consist of four candidates from both the ruling CPP and opposition CNRP, as well as a final member acceptable to both parties.

Ms. ChhivKek accepted the "neutral" position on the NEC last year but on Tuesday released a statement reversing her decision, saying that the position on the NEC would not guarantee the independence promised when she had accepted it.

On Tuesday evening, the CPP circulated a letter from Prime Minister Hun Sen to opposition leader Sam Rainsy, dated Sunday, identifying Mr. Puthea as her replacement.

"Following correspondence between Your Excellency and myself by phone messaging on March 29, 2015, our two parties have agreed to choose Hang Puthea, executive director of the Neutral and Impartial Committee for Free and Fair Elections (Nicfec) to be the ninth candidate on the National Election Committee," Mr. Hun Sen wrote.

"Therefore, please, Your Excellency, review and sign this letter to send it to the National Assembly standing committee

Continued to Page 16

## តមកពីទំព័រទី ០៩ បុណ្យអ៊ីសស្ទើរ

ថ្ងៃបន្ទាប់មក.គាត់ក៏ត្រូវរងការកាត់ទោសដំដែកជាប់ទៅ និងឈើឆ្កាង។ ពេលដែលគាត់ស្លាប់រួច.មិត្តភ័ក្តរបស់គាត់ក៏បាននាំយកទៅបូជានៅក្នុងរូងភ្នំមួយ រួចបានយកផ្ទាំងថ្មធំៗបិទជិតមាត់រូង. នៅថ្ងៃអាទិត្យមិត្តភ័ក្តរបស់គាត់ក៏បានធ្វើដំណើរវិលមកមើលរូងភ្នំនោះវិញ. គេបានប្រទះឃើញផ្ទាំងថ្មទាំងនោះរបើកចេញពីមាត់រូង រួចសាកសពយ៉េស៊ូពីក៏បាត់រូងភ្នំនោះទៅ.ក្រោយមក. យ៉េស៊ូក៏បានបង្ហាញខ្លួនចំពោះមុខបរិស័ទរបស់គាត់បង្ហាញថាគាត់រស់ឡើងវិញ ព្រោះខ្លួនគាត់ជាកូនរបស់ព្រះអាទិទេព ដូចបាននិយាយក្នុងគម្ពីរបាយ បីល (bible)។

ថ្ងៃដែលព្រះយ៉េស៊ូស្លាប់គឺថ្ងៃសុក្រ. រីឯថ្ងៃដែលរស់ឡើងវិញគឺថ្ងៃអាទិត្យអ៊ីសស្ទើរ. បុណ្យអ៊ីសស្ទើរមិនបានកំណត់ថ្ងៃទៀងទាត់នោះទេ. ធម្មតាមុន ឬក្រោយថ្ងៃទី២១ខែមីនា. អនុលោមទៅតាមច័ន្ទគតិ គឺយកថ្ងៃអាទិត្យមុន ឬក្រោយថ្ងៃពេញបូណ៌មី.ឆ្នាំនេះបុណ្យអ៊ីសស្ទើរប្រារព្ធនៅថ្ងៃទី៥ ខែមេសា (ទោះជាយ៉ាងនេះក៏ដោយ. នៅវិហារអរ័ថរ័ដក គេនិងធ្វើបុណ្យក្រោយ១សប្តាហ៍. ព្រោះយោងតាមប្រកតិទិនមានភាពខុសៗគ្នា)...

មួយចំនួននៃអ្នកកាន់សាសនានេះ. មិនប្រារព្ធធ្វើតាមប្រពៃណីបុណ្យអ៊ីសស្ទើរឡើយ ពួកគេអនុលោមទៅតាមប្រពៃណីអាល្លឺម៉ង់នៅសម័យបូរាណ. គេនិងធ្វើនៅចុងរដូវរងា ពេលស្លឹកឈើរលស់ថ្មី. ជាឧទាហរណ៍: ប្រជារាស្ត្រអាល្លឺម៉ង់មានជំនឿថា: រាត្រីមុនថ្ងៃបុណ្យអ៊ីសស្ទើរ និងមានទន្សាយសីលយូរកន្ត្រកចូលមកក្នុងផ្ទះជូនស្ករគ្រាប់ និងរង្វាន់ដល់កូនក្មេងណាដែលចេះសុភាពរាបសាក្នុងរយៈពេល១ឆ្នាំកន្លងមក.នោះជាដើមកំណើតនៃនិមិត្តរូបបុណ្យអ៊ីសស្ទើរទន្សាយ និងបុណ្យអ៊ីសស្ទើរកន្ត្រក. ក្នុងពេលជាមួយគ្នានេះដែរ. វិន័យសាសនាហាមមិនឱ្យហូបស៊ុត(មានពងមាន់ពងទា ។ល។) ក្នុង១សប្តាហ៍មុនថ្ងៃបុណ្យអ៊ីសស្ទើរមកដល់. ម៉្លោះហើយពួកគេក៏នាំគ្នាស្ងោរស៊ុតទុកបំរុងជាមុន លុះឆ្លងបុណ្យអ៊ីសស្ទើរទើបគេយកមកហូប. នោះជាដើមកំណើតនៃនិមិត្តរូបបុណ្យអ៊ីសស្ទើរស៊ុត. តាមប្រពៃណី. ម្ហូបហាម(ហាម) សម្រាប់ហូបនៅថ្ងៃបុណ្យអ៊ីសស្ទើរ។ ពីព្រោះម្ហូបហាមគេអាចរក្សាទុកបានពេលយូរក្នុងរដូវរងា។ ក្នុងសាសនាគ្រីស្ត្រ. បុណ្យអ៊ីសស្ទើរជាបុណ្យចុងក្រោយបំផុតក្នុងឆ្នាំ. ក៏ជាបុណ្យតាមទំនៀមទំលាប់នៅចុងរដូវរងា និងឈានចូលរដូវស្លឹកឈើរលស់ថ្មី. ដូចគ្នានិងវប្បធម៌នៃសាសនាដទៃដែរ ៕



តមកពីទំព័រទី ០៨

## បទសម្ភាសន៍ជាមួយលោក កឹម សុខា...

រីឯថ្ងៃសម្រេចថា ត្រូវអនុមតិច្បាប់ទើបនឹងសម្រេចយកនៅពី-បីថ្ងៃមុននេះ ទេ

**សួរ:** តើបើលោកនៅក្រៅប្រទេសមានប៉ះពាល់អ្វីដល់ការអនុមតិច្បាប់នោះទេ?

**កឹម សុខា:** ច្បាប់នោះសម្រេចដោយមតិភាគច្រើនឱ្យតែមានសមាជិកភាគច្រើន គឺ៦២នាក់អនុម័ត គឺច្បាប់នោះប្រើបានហើយ... ហើយម្យ៉ាងទៀតដោយច្បាប់នោះចេញពីការចរចាហើយព្រមព្រៀងរវាងគណបក្សទាំងពីររួចទៅហើយនោះនឹងមិនមានការជជែកវែកញែកអ្វីក្នុងប្រជុំពេញអង្គទៀតទេ ។

**សួរ:** មុននឹងអនុម័តច្បាប់បន្តិចលោក ហ៊ុន សែន ទាមទារឱ្យដាក់មាត្រាមួយអនុញ្ញាតឱ្យអាចដកអាសនពីគណបក្សណាដែលមិនព្រមចូលសភាតាមសេចក្តីអញ្ជើញរបស់ព្រះមហាក្សត្រឱ្យមកបើកសភាដំបូងតើនេះបានន័យថា លោក ហ៊ុន សែន នៅតែជឿជាក់ថា គណបក្សលោកនឹងនៅតែឈ្នះឆ្នោតដដែល ឬក៏មានល្បិចយ៉ាងណាផ្សេងពីនេះ?

**កឹម សុខា:** នេះជាបញ្ហាការជាប់គាំងបន្ទាប់ពីការបោះឆ្នោតហើយបានន័យថានៅពេល គ.ជ.ប.ប្រកាសលទ្ធផលហើយព្រះមហាក្សត្រចេញសេចក្តីអញ្ជើញសមាជិកសភាជាប់ឆ្នោតនោះមកបើកសន្និបាទសភាដំបូងបើមានសមាជិកសភាធ្វើពហិការមិនព្រមចូលសភាពេលនោះគ.ជ.ប.ចាត់ទុកថា បោះបង់អាចនឹងប្រកាសដកអសនៈចេញពីគណបក្សនៃសមាជិកសភានោះបាន...តែករណីនេះយើងបានបន្ថែមដោយមាត្រាមួយដែលអាចអនុវត្តន៍លើគណបក្សប្រជាជនវិញបានដែរនិយាយថា អាចនឹងដកអាសនៈបានលុះត្រាណាតែការបោះឆ្នោតមានលក្ខណសេរីត្រឹមត្រូវ និងយុត្តិធម៌ ដូច្នេះបើការបោះឆ្នោតនោះសេរីត្រឹមត្រូវនឹងយុត្តិធម៌ហើយ គឺគណបក្សសង្គ្រោះជាតិទេ ជាអ្នកឈ្នះអានេះនឹងក្លាយជាចំណោះជិះកឯងទៅវិញទេ។

**សួរ:** សំនួរមួយនេះខ្ញុំតែងតែតែសួរថ្នាក់ដឹកនាំគណបក្សសង្គ្រោះជាតិដោយសារមនុស្សថ្មីពេលវេលាថ្មីដំណោះស្រាយថ្មីឆ្លើយតបនឹងកង្វល់ពលរដ្ឋដែលចង់បានការផ្លាស់ប្តូរថាតើគណបក្សសង្គ្រោះជាតិនៅពេលឈ្នះឆ្នោតនឹងយកអំណាចបានដោយរបៀបណាបើរចនាសម្ព័ន្ធសង្គមនយោបាយសេដ្ឋកិច្ចនៅបំរើតែគណបក្សប្រជាជនតែមួយនោះ?

**កឹម សុខា:** យើងមិនអាចទស្សន៍ទាយមុនបានទេតែយើងដឹងថា កត្តាពដែលអាចឱ្យយើងសង្ឃឹមថាយកបានគឺ ១-នៅគណបក្សប្រជាជនក៏មានអ្នកចង់ផ្លាស់ប្តូរដែរយើងឃើញហើយថាទោះបីជាក្នុងតំបន់គ្រប់គ្រងដោយគណបក្សប្រជាជនក៏សង្គ្រោះជាតិឈ្នះដែរដូច្នេះក៏អាចមានការផ្ទេរអំណាចដោយស្រួលបាន ២-គឺខ្លួនយើងយើងត្រូវបង្ហាញថា យើងនឹងគ្មានការគំកួនហើយចាត់ទុកនរណាម្នាក់ជាសត្រូវតែបើយើងអួតអាងថាដល់អញឈ្នះអញនឹងសងសឹកអ្នកនេះអ្នកនោះគេនឹងក្រាញមិនឱ្យយើងឈ្នះទេ ៣-កត្តាអ្នកនៅជុំវិញយើងនៅពេលឃើញយើងឈ្នះតើគេនៅតែកាន់ជើងគណបក្សប្រជាជនតទៅទៀតឬក៏គេអាចបែរមករកយើងដូចជាចិន ឬយួនជាដើម...

**សួរ:** ខ្ញុំនៅចងចាំថា នៅឆ្នាំ១៩៩៣-៩៤ លោក សម រង្ស៊ី កាន់តំណែងជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុលោកបានបង្ហាញនយោបាយស្អាតស្អំរបស់ក្រសួងដោយកំចេញកំចាត់អំពើពុករលួយគ្រប់ទិកន្លែងដូចជាកាប់ព្រៃឈើរត់ពន្ធត្រួតពិនិត្យក្រុម"តៃគួន"លើសម្បត្តិជាតិតែទទួលបាននូវការតបតដៃយ៉ាងក្តៅមកវិញ ដូចជាបាញ់លើរថយន្តបាញ់នាវាយោធាដែលលោកជិះពីសំណាក់បណ្តាញជនបំផ្លាញជាតិប៊ិះស្លាប់ប៊ិះរស់ តើគណបក្សសង្គ្រោះជាតិនឹងទប់ស្កាត់យោធាការពារបរទេសមន្ត្រីពុករលួយពួកឧកញ៉ាដឹកនាំជាតិទៅរកមហន្តរាយនៅពេលឈ្នះទៅកាន់អំណាចរបៀបណា?

**កឹម សុខា:** ខ្ញុំនៅតែយល់ថា គណបក្សសង្គ្រោះជាតិត្រូវតែបន្តនយោបាយអភិវឌ្ឍន៍ជាតិដោយត្រជាក់អហឹង្សាមិនមានការគុំគួនសងសឹកទើបបំបាត់ការក្តៅក្រហាយបានខ្ញុំបានផ្តើមនិយាយគំនិតនេះតាំងតែពីនៅគណបក្សសិទ្ធិមនុស្សមកម្ល៉េះ ឥឡូវលោក សម រង្ស៊ី ក៏ចាប់ផ្តើមនិយាយភាសាដូចគ្នា ហើយយើងត្រូវស្វែងរកការរស់នៅសុខដុមរមនាជាមួយគ្នា...មិនទាន់បានអីផងយើងចាប់អនុវត្តន៍ក្តៅក្រហាយគេមិនឱ្យយើងសុខមិនឱ្យយើងមានពេលអនុវត្តន៍នយោបាយអភិវឌ្ឍន៍ជាតិឱ្យបានសុខដុមសន្តិភាពនឹងសមភាពបានទេ ខ្ញុំនឹងមិនធ្វើអ្វីដែលក្តៅក្រហាយនោះទេយើងមានវិធីដោះស្រាយផ្សេងពីនេះទៀត ។

**សួរ:** មានទស្សនខ្លះគិតថា សម រង្ស៊ី និង កឹម សុខា ក៏អាចនឹងបែកបាក់គ្នាបានដែរ តើចំណុចដែលអាចបំបែកបាននោះគឺអ្វីទៅ?

**កឹម សុខា:** មិនថាតែ កឹម សុខា និង សម រង្ស៊ី ទេ ដែលអាចបែកគ្នាបាននោះ ពីព្រោះយើងមានប្រភពខុសគ្នាមានគំនិតប្លែកពីគ្នាសូម្បីតែជាប្តីប្រពន្ធក៏បែកគ្នាបានដែរ! ក៏ប៉ុន្តែប្តីប្រពន្ធដែលមាន គោលដៅតែមួយ គឺគិតពីអនាគតកូនខ្លួននោះនឹងមិនបែកគ្នាទេ... យ៉ាងណាមិញ សម រង្ស៊ី-កឹម សុខា យើងមានគោលដៅដូចគ្នា គឺសង្គ្រោះជាតិសង្គ្រោះប្រជាពលរដ្ឋហេតុនេះហើយបានជាយើងត្រូវរួមកម្លាំងគ្នាបើយើងបែកគ្នាមិនអាចសង្គ្រោះជាតិបានទេ

**សួរ:** គណបក្សប្រជាជនកំពុងតែគិតថាគណបក្សសង្គ្រោះជាតិអាចនឹងយកសន្លឹកឆ្នោតបានច្រើន ហើយអាចឈ្នះឆ្នោតទៀតផង ហេតុនេះហើយបានជាគេខំប្រឹងតម្លើងឥទ្ធិពលតម្លើងគណបក្សហ្វ៊ុនស៊ិនប៉ិចឡើងវិញ គេអាចមើលឃើញថា ជាកលល្បិចដើម្បីបំបែកសន្លឹកឆ្នោតពីគណបក្សសង្គ្រោះជាតិឱ្យគណបក្សប្រជាជននៅតែឈ្នះឆ្នោតដដែល តើឯកឧត្តមមើលឃើញថា តើគណបក្សហ្វ៊ុនស៊ិនប៉ិចអាចងើបរួចឬទេ ?

**កឹម សុខា:** មកទល់ថ្ងៃនេះខ្ញុំមិនទាន់ឃើញគណបក្សណាដែលអាចកើតឡើង ហើយដណ្តើមសន្លឹកឆ្នោតពីគណបក្សសង្គ្រោះជាតិបាននៅឡើយទេ ដូចជាគណបក្សហ្វ៊ុនស៊ិនប៉ិចរបស់សម្តេចក្រុមព្រះក៏គេស្គាល់អស់ទៅហើយដែរ ប្រជា-ពលរដ្ឋគេមិនបោះឆ្នោតឱ្យទេលើកលែងតែមួយគឺគណបក្សសង្គ្រោះជាតិបែកបាក់គ្នាអានេះវានៅនឹងខ្លួនយើងទេ បើយើងធ្វើឱ្យវាបាត់ គឺវាបាត់ហើយតែបើយើងធ្វើមិនឱ្យបាត់មិនអាចគណបក្សទីពាណាយកបានទេ

**សួរ:** តើខាងក្រុមសហជីពកម្មករក្រុមសកម្មជនដីធ្លីដែលសព្វថ្ងៃធ្វើការបះបោរតែដោយខ្លួនឯងបានរាប់ពាន់ម៉ឺននាក់ដែរនោះអាចក្លាយជាកម្លាំងគណបក្សថ្មីមួយហើយបំបែកឆ្នោតពីសង្គ្រោះជាតិបានទេ? នេះក៏ព្រោះតែធ្លាប់មានប្រធានសហជីពកម្មករនៅអឺរ៉ុបខាងលិចមួយរូបបានក្លាយជាប្រធានាធិបតីនៃប្រទេសខ្លួនដោយសារតែដឹកនាំចលនាបាតុកម្មដ៏មានប្រជាប្រិយភាពនោះ

**កឹម សុខា:** វាអាច! ខ្ញុំក៏បានដឹងពីចលនានោះដែរ ហើយបានសិក្សាពីចលនារបៀបនេះកាលពីខ្ញុំនៅជាអង្គការសិទ្ធិមនុស្សទាំងនេះអាស្រ័យកត្តាជាច្រើនយ៉ាងទៀតថា តើបុគ្គលនោះមានការប្តេជ្ញាចិត្តមានការតស៊ូមានសេចក្តីក្លាហានមានសមត្ថភាពគ្រប់គ្រាន់សម្រាប់ទប់ទល់នឹងឧបសគ្គដែរ ឬអត់ ? ប្រជាពលរដ្ឋនឹងធ្វើការប្រៀបធៀបជាមួយនឹងខ្ញុំ ឬ សម រង្ស៊ី ថាតើនរណាអាចការពារផលប្រយោជន៍ជាតិបានប្រសើរជាង?

**សួរ:** តើឧត្តមឯកប្រឆាំងនឹងចលនានោះឬទេ?

**កឹម សុខា:** ប្រឆាំងយ៉ាងម៉េច?

**សួរ:** ប្រឆាំងនឹងកំណើតនៃគណបក្សដែលកើតពីសហជីពកម្មករនេះ?

**កឹម សុខា:** វាមានលក្ខណៈច្រើនយ៉ាងនៃការថា ប្រឆាំងនេះថា តើគណបក្សនោះកើតឡើងរបៀបណា? ជាគូរប្រកួត ឬក៏ជាគូរគាំទ្រ? បើមកជាគណបក្សប្រកួតយើងនឹងតស៊ូប្រកួត ហើយតែបើចរន្តដូចគ្នាយើងនឹងធ្វើការជាមួយគ្នា

**សួរ :** នៅពេលបើកឱ្យយុទ្ធនាការឃោសនាខាងមុខតើគណបក្សសង្គ្រោះជាតិមានធនធានគ្រប់គ្រាន់សម្រាប់ទប់ទល់នឹងក្រុមឃោសនាគណបក្សប្រជាជនដែលមានលុយវាល់កោដិដែរ ឬទេ?

**កឹម សុខា:** ឥឡូវនេះពុំមែនលុយទេ ដែលជាកត្តាសំខាន់សំរាប់ឈ្នះឆ្នោតនោះទេ! ប្រជា-ពលរដ្ឋឥឡូវបានដឹងអស់ហើយពីរឿងសារ៉ុង ឬ ប៊ីចេងអីនោះ ។ ឥឡូវនេះគណបក្សសង្គ្រោះជាតិមានសមត្ថភាពនឹងធនធានសម្រាប់ធ្វើការឃោសនាដោយខ្លួនឯងបានហើយ

**សួរ:** មុននេះបន្តិចមុននឹងចេញដំណើរពីឡូវែលត្រឡប់ទៅភ្នំពេញវិញ ព្រះអង្គម្ចាស់ស៊ីសុវត្ថិធម្មិកោមានបន្ទូលថា គណបក្សប្រជាជនធ្លាប់មានអ្នកគាំទ្រជាប្រចាំតែ៣០-៣៥ភាគរយទេ ហើយចំនួននេះក៏កំពុងតែស្រុតចុះដោយសារមូលដ្ឋានបាត់ជំនឿ តើឯកឧត្តមគាំទ្រវិភាគនេះទេ?

**កឹម សុខា:** ខ្ញុំក៏ធ្លាប់និយាយយូរហើយថាគណបក្សប្រជាជនបានយ៉ាងច្រើន៣០-៣៥កៅអីតែប៉ុណ្ណោះ ដូច្នេះព្រះអង្គម្ចាស់មានបន្ទូលដូចតែគ្នាទេ។

**ពិន សំខុន:** សូមអរគុណហើយជូនពរឱ្យបានជោគជ័យ!


ការិយាល័យច្បាប់
រ៉ូសា និង តាំង


Francisco J. Rosa, Esq.
មេធាវី ហ្វ្រង់ ស៊ីស្កូ ជេ.រូសា


Andrew 'Bunna' Taing, Esq.
មេធាវី អែន ឌ្រីវប៊ុណ្ណា តាំង

Law Office of
Rosa & Taing
ATTORNEY AT LAW

| SERVICES | តំណាងក្តីដូចខាងក្រោម |
| --- | --- |
| Auto Accidents/ Personal Injury | គ្រោះថ្នាក់រថយន្ត/ របួសរូបរាងកាយ |
| Bankruptcy | ក្ស័យធន |
| Immigration | អន្តោប្រវេសន៍ |
| Consumer Protection | ការពារអតិថិជន |
| Real Estate Closings/Disputes | ទំនាស់ផ្នែកអចលនវត្ថុ |
| Divorces Child Custody | លែងលះ និងអាណាព្យាបាលកិច្ច |

1550 Middlesex Street Lowell, MA 01851
Phone: **978-458-0934** | help@attorneyrosa.com
www.attorneyrosa.com

តមកពីទំព័រទី ០៧

## "កុំស្មានបងភ្លេច"ខ្មែរបាត់បង់តន្ត្រីរ៉ក់...

ជីវិតដល់សព្វថ្ងៃមានលោក ម៉ុល កាម៉ាច និងលោក ម៉ុល កាញ៉ុល ដែលជាបងប្អូនបង្កើត។ ក្នុងឆ្នាំ១៩៥៩ លោកទាំងពីរបានបង្កើតវង់ភ្លេងមួយមានឈ្មោះថា បក្សីចាំក្រុងដែលគេឧទ្ទិសនាមថា ជា "ជីប៊ីថើលខ្មែរ"។ បទចម្រៀងល្បីរបស់លោក ម៉ុល កាម៉ាច មានដូចជា "ព្រែកឯងអស់សង្ឃឹម" និង "សូមលាអ្នកមានគុណ"។ លោក ហុង សំលី ក៏លេចមុខក្នុងជំនាន់ដដែលជាមួយ "ជីប៊ីថើលខ្មែរ" មួយទៀត ដ៏មានប្រជាប្រិយដូចគ្នា គឺក្រុមយុវតន្ត្រីករ "អប្សរា" ដែលគេនៅចងចាំនៅឡើយបទ"អានី"នឹងបទ "បាត់អូន" ជាដើម។




ក្រុមតន្ត្រីករ និងអ្នកចម្រៀងក្នុងវង់ភ្លេង ជ្រាក្ការ ដូចជា លោក ទូច ថាណា លោក អ៊ុក សំអាត (ហៅថុល) និងលោក ទូច ឆាត់ថា (ហៅឆាត់) ក៏នៅរស់រានមានជីវិតនៅឡើយដែរ។ បទល្បីរបស់វង់ភ្លេង ជ្រាក្ការ ដែលច្រៀងដោយលោក ទូច ថាណា មានដូចជាបទ "ឆ្កួតចិត្ត ត្បិតស្នេហ៍អូន"។ នៅនាង ឆោម និមល មួយទៀតជាពន្លកតារាទំពាំងស្នងឫស្សី កូនស្រីរបស់ ឆោម ឆវិន តារា ចម្រៀងបំពេរអារម្មណ៍ជំនាន់មុនក៏មកក្រុងឡូវែលដែរ។

ក្រុមតន្ត្រីករ និងអ្នកចម្រៀងដ៏កម្រទាំងនេះ កំពុងធ្វើដំណើរមកទីក្រុងឡូវែលក្នុងចុងខែមេសា នេះ ដើម្បីសម្តែងតន្ត្រីជាផ្នែកមួយក្នុងដំណើរប្រគុំតន្ត្រី និងបញ្ចាំងខ្សែភាពយន្តឯកសារ "កុំស្មានបងភ្លេចៈ ខ្មែរបាត់បង់តន្ត្រីរ៉ក់"។ ភាពយន្តឯកសារនេះ គឺជាការចងក្រងនូវប្រវត្តិនៃភាពល្បីរន្ទឺរបស់តន្ត្រីរ៉ក់ខ្មែរក្នុងទសវត្សឆ្នាំ១៩៦០ទាំងមូល។ តទៅទំព័រទី ១៩

Continued from page 09

## Lowell Celebrates Cambodia's

of its popular music stars of the 50s, 60s, and 70s, the acclaimed documentary "Don't Think I've Forgotten: Cambodia's Lost Rock and Roll" examines and unravels Cambodia's tragic past while paying homage to the creative burst of music that influenced a generation. Combining interviews with surviving musicians, never-before-seen archival material, and rare songs, the film tracks the winding course of Cambodian music as it morphed into its own unique style of rock and roll. A vibrant musical culture that was nearly lost forever under the brutal Khmer Rouge regime is revived!

A labor of love by director John Pirozzi, "Don't Think I've Forgotten: Cambodia's Lost Rock and Roll" screens in Lowell April 24th - 30th at Lowell's Showcase Cinemas (32 Reiss Avenue) with special screenings on Saturday, April 25th (7pm) and Sunday, April 26th (3:30pm) that will feature Guest Appearances by director John Pirozzi and the musical artists featured in the film who survived the Khmer Rouge massacre: MolKamach, MolKagnol, Samley Hong, Tana, Touch Chhattaha, and Ouk Sam Art.

On Sunday, April 26th, a once-in-a-lifetime Live Musical Revue and Concert featuring these esteemed musical artists will be held at the SampaoMeas Hall, 450 Chelmsford Street, in Lowell. The incredible program will showcase the great music of Cambodia's rock and roll era and will also feature "The Songs of Sinn Sisamouth" sung by Sisamouth's grandson, Sinn Sethakol, and "The Songs of RosSereySothea," performed by ChhomNimol, the dynamic lead singer of the band Dengue Fever.

Tickets for this special event are $30.00 per person and include a 4-course sit-down Cambodian dinner. Tickets can be purchased online at www.dtiflowell-concert.eventbrite.com. Doors open at 6pm, dinner served at 6:30pm, and the concert will begin at 7:30pm. A cash bar will also be available.

Tickets to all the film screenings at Lowell Showcase Cinema can be purchased at the cinema or online at www.ShowcaseCinemas.com.

A Welcome Event & Brunch for the visiting musicians will be held on Sunday, April 26th at 11:30am, and will feature a live musical performance by the UMass Lowell ensemble "Battambang Bam Boom" who specialize in Cambodia's vibrant rock and roll music of the 60s and 70s. The event will be FREE and open to the public at Simply Khmer Restaurant.

Presenting partners for the "Don't Think I've Forgotten" events are UMass Lowell, KhmerPost USA, and is hosted by The Lowell Film Collaborative. For more information, please visit www.LowellFilmCollaborative.org


វិជ្ជាស្ថានរៀន
ថែសម្ផស្សមុខនិងត្រចក

ទើបបើកថ្មី

Chelmsford Beauty Academy

60 Chelmsford St.,2nd Floor Chelmsford, MA. 01824
Tel: (978)328-9722 ឬ (978) 250-4488





- យើងខ្ញុំបានបើកវគ្គបង្រៀនធ្វើត្រចក និងថែសម្ផស្សមុខ គ្រូបង្ហាត់ មានការដកពិសោធន៍ច្រើនឆ្នាំ មានថ្នាក់រៀនក្រៅម៉ោង និងពេញម៉ោង៧ថ្ងៃក្នុង១សប្តាហ៍
- យើងខ្ញុំបើកវគ្គសិក្សា៣០០ម៉ោង សម្រាប់ថ្នាក់ថែសម្ផស្សមុខ និងវគ្គ ១០០ម៉ោង
- សម្រាប់ថ្នាក់ធ្វើត្រចក។
- សូមចុះឈ្មោះជាប្រញាប់ !

ជួយណែនាំរកការងារធ្វើ
ពេលចប់ការសិក្សា

Chelmsford Beauty Academy មានចម្ងាយ៥នាទីពីក្រុង Lowell,
និង១៥នាទីពីក្រុង Lawrence, ចម្ងាយ១០នាទីពី Burlington Mall, និង១០នាទី Andover.

ព័ត៌មានបន្ថែមទាក់ទងជាមួយយើងខ្ញុំថ្ងៃនេះតាមទូរស័ព្ទលេខ : (978)328-9722 ឬលេខ : (978)250-4488

# សេចក្តីអញ្ជើញរបស់ក្លឹបសារព័ត៌មាន
# PRESS CLUB INVITATION

Dear Friends, Community Members and Leaders:

Please join us on **Thursday, April 9, 2015** from **noon until 2 pm** at Lowell Telecommunications, **246 Market St in Lowell,** for the next KhmerPost USA PRESS CLUB event.

•The first portion of this PRESS CLUB will review and discuss the proposal to install a Cambodian monument on Lowell City Hall Plaza.

•The second part of the meeting will continue the discussion began at previous PRESS CLUBS between Cambodian business owners and city officials about the challenges faced by these businesses and about how city government can assist.

PRESS CLUB provides a valuable opportunity for the Cambodian community and government officials in Lowell to learn more about the challenges each face and to improve overall communications. Because the KhmerPost USA publishes articles about what is discussed at these meetings, the information is shared with the entire Cambodian community. Please consider joining us on April 9th.

• Lunch will be served.

Sincerely Yours,

*Soben Pin*

Soben Pin, Managing Partner
KhmerPost USA, LLC,
45 Merrimack St. Ste. 218A
Lowell, MA 01852



សមាជិក.អ្នកដឹកនាំ ព្រមទាំងមិត្តទាំងអស់ ជាទីរាប់អាន

សូមអញ្ជើញចូលរួម"ប្រេសក្លឹប"ជាមួយយើងខ្ញុំ **នៅថ្ងៃព្រហស្បតិ៍ ទី៩ មេសា ឆ្នាំ២០១៥, វេលាម៉ោង២រសៀល** នៅអាសយដ្ឋាន : LTC 246 Market St in Lowell

•ក្នុងភាគដំបូងនៃ"ប្រេសក្លឹប" និងធ្វើការពិភាក្សាគំរោងសាងរូបវិមានដែលត្រូវសង់ឡើងនៅទីលានមុខសាលាក្រុងឡូវែល ។

•ក្នុងភាគទី២ និងលើកយកបញ្ហាអាជីវកម្មដែលបានធ្វើការពិភាក្សាក្នុង"ប្រេសក្លឹប"គ្រាកន្លងមក រវាងអាជីវកម្មខ្មែរ និងមន្ត្រីរដ្ឋបាល. ថាៈ តើមានអ្វីដែលរដ្ឋបាលក្រុងអាច និងជួយបានទៀត ។

ក្លឹបសារព័ត៌មានឬ"ប្រេសក្លឹប" ផ្តល់ឱកាសដល់សហគមន៍ខ្មែរ និងរដ្ឋបាល ក្រុងឡូវែល ធ្វើបទសិក្សារាល់ជ្រុងជ្រោយ ដើម្បីរកភាពចម្រើន សម្រាប់សហគមន៍ធ្វើការវិវឌ្ឍទៅមុខ ។ កាសែតខ្មែរផុស និងលើកមកចុះផ្សាយនូវអត្ថន័យក្នុងកិច្ចពិភាក្សា "ប្រេសក្លឹប" នេះ, ផ្សព្វផ្សាយទូទាំងសហគមន៍ខ្មែរឱ្យបានដឹង ។

លោក ហ៊ុន សែន បានសរសេរថា "ក្រោយពីការឆ្លើយឆ្លងរវាងឯកឧត្តម និងខ្ញុំតាមសារទូរស័ព្ទកាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៥ គណបក្សយើងទាំងពីរបានព្រមព្រៀងជ្រើសរើសលោក ហង្ស ពុទ្ធា នាយកប្រតិបត្តិនៃគណៈកម្មាធិការអព្យាក្រឹត និងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជាឱ្យធ្វើជាបេក្ខជនសមាជិកទី៩នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ដូចនេះសូមឯកឧត្តមពិនិត្យ និងចុះហត្ថលេខាលើលិខិតនេះដើម្បីទុកបញ្ជូនទៅគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភានៅក្រោយពេលរដ្ឋសភាបញ្ចប់ការទទួលពាក្យសុំឈរឈ្មោះជាបេក្ខជនសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត"។

លោក សម រង្ស៊ី បានបញ្ជាក់ពីការជ្រើសរើសនេះកាលពីល្ងាចម្សិលមិញ។ លោកបានមានប្រសាសន៍ថា "ខ្ញុំសូមបញ្ជាក់ថា លោក ហង្ស ពុទ្ធា គឺជាអ្នកដែលនឹងជំនួសតំណែងលោកស្រី ពុង ឈីវកេក" ដោយលោកបានពន្យល់ថា បទ-ពិសោធរបស់លោក ហង្ស ពុទ្ធា ជាអ្នកឃ្លាំមើលការបោះឆ្នោត និងជាប្រធានអង្គការមិនមែនរដ្ឋាភិបាលបានធ្វើឱ្យលោកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ទទួលយកមុខតំណែងនេះ។

លោកបានមានប្រសាសន៍ថា "គាត់គឺជាបេក្ខជនល្អបំផុតទី២បន្ទាប់ពីលោកស្រី ពុង ឈីវកេក មកពីអង្គការលីកាដូ ដូច្នេះគាត់ស្ថិតនៅក្នុងលេខរៀងទី២ ដូច្នេះហើយគ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេ"។

លោក ហង្ស ពុទ្ធា ដែលអង្គការមិនមែនរដ្ឋាភិបាលរបស់លោកបានស្ថិតក្នុងចំណោមអង្គការជាច្រើនដែលបានរិះគន់ច្បាប់បោះឆ្នោតថ្មីទាំងពីរនេះ បានមានប្រសាសន៍កាលពីម្សិលមិញថា គណបក្សទាំងពីរមិនទាន់បានទាក់ទងទៅលោកទេជុំវិញការតែងតាំងនេះ។

លោកបានមានប្រសាសន៍យ៉ាងដូច្នេះថា "មានតែប្រព័ន្ធផ្សាយប៉ុណ្ណោះដែលបានសួរខ្ញុំជាច្រើនអំពីបញ្ហានេះនៅថ្ងៃនេះ ប៉ុន្តែខ្ញុំមិនទាន់ទទួលបានព័ត៌មានណាមួយពីគណបក្សទាំងពីរនៅឡើយទេ។ ខ្ញុំត្រូវការពេលវេលាដើម្បីពិភាក្សារឿងនេះជាមួយសហសេវិក ពីព្រោះខ្ញុំមិនទាន់បានត្រៀមខ្លួនក្លាយជាសមាជិកគ.ជ.ប. នៅឡើយទេ"។

លោក ឈឹម ផលវរុណ អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជាបានមានប្រសាសន៍ថា ការសម្រេចជ្រើសរើសលោក ហង្ស ពុទ្ធា ជំនួសតំណែងលោកស្រី ពុង ឈីវកេក ត្រូវបានធ្វើឡើងកាលពីសប្តាហ៍មុន ប៉ុន្តែថាគណបក្សទាំងពីរបានសម្រេចមិនផ្សព្វផ្សាយជាសាធារណៈទេរហូតទាល់តែលោកស្រី ពុង ឈីវកេក សម្រេចចិត្តជាផ្លូវការ។

លោកបានមានប្រសាសន៍ទៀតថា "តាមពិតការសម្រេចជ្រើសរើសលោក ហង្ស ពុទ្ធា ត្រូវបានធ្វើឡើងប្រហែលមួយសប្តាហ៍មុន បន្ទាប់ពីដឹងព័ត៌មានក្រៅផ្លូវការថា លោកស្រី ពុង ឈីវកេក នឹងបដិសេធតំណែងនេះ។ ចាំបាច់ត្រូវរក្សាការសម្ងាត់ជាមុនសិនដោយខ្លាចធ្វើឱ្យប៉ះពាល់ដល់សិទ្ធិបុគ្គលឱ្យ ប៉ុន្តែ"ពេលនេះលោកស្រីបានប្រកាសបដិសេធជាសាធារណៈ និងជាផ្លូវការហើយ"។

លោកបានបន្តថា លោក ហង្ស ពុទ្ធា ត្រូវដាក់ពាក្យសុំដើម្បីក្លាយជាសមាជិក គ.ជ.ប. ប្រសិនបើលោកទទួលយកការតែងតាំងនេះ។ លោកបានបន្តថា "គាត់គឺជាមនុស្សដែលមានការអប់រំខ្ពស់មានសញ្ញាបត្រថ្នាក់បណ្ឌិត ហើយគាត់មានបទពិសោធន៍ច្រើន និងប្រកាន់ជំហរអព្យាក្រឹត។ នោះជាមូលហេតុដែលថ្នាក់ដឹកនាំនៃគណបក្សទាំងពីរបានសម្រេចគាំទ្រគាត់ឱ្យធ្វើជាសមាជិកទី៩របស់ គ.ជ.ប."។

លោកស្រី ពុង ឈីវកេក ដែលនៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០ ធ្លាប់រៀបចំឱ្យមានការចរចាគ្នារវាងព្រះអង្គម្ចាស់នរោត្តម សីហនុ និងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានជួយបញ្ចប់សង្គ្រាមស៊ីវិលក្នុងប្រទេសកម្ពុជាបានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍របស់លោកស្រីថា គួរឱ្យសោកស្តាយណាស់ដែលលោកស្រីសម្រេចចិត្តបដិសេធមិនទទួលយកអាសនៈអព្យាក្រឹតរបស់ គ.ជ.ប. នេះ។

លោកស្រីបានលើកឡើងយ៉ាងដូច្នេះថា "ទោះបីវាជាកិត្តិយសដ៏ធំធេងដែលត្រូវបានជ្រើសរើសសម្រាប់មុខតំណែងដ៏សំខាន់នេះក្តី ក៏ខ្ញុំមានការសោកស្តាយយ៉ាងខ្លាំងដែលខ្ញុំត្រូវបដិសេធការផ្តល់ឱកាសធ្វើជាសមាជិកទី៩នៃគ.ជ.ប.ថ្មី។ ខ្ញុំសូមអភ័យទោសចំពោះជនរួមជាតិដែលមានជំនឿមកលើខ្ញុំ និងអ្នកដែលខ្ញុំធ្វើឱ្យខកចិត្ត"។

លោកស្រីបានទទួលយកតំណែងនេះមិនយូរប៉ុន្មានក្រោយពីមានកិច្ចព្រមព្រៀងនយោបាយថ្ងៃ២២ កក្កដា អមដោយលក្ខខណ្ឌមួយចំនួនរួមទាំងការផ្តល់អភ័យឯកសិទ្ធិដល់លោកស្រី ដើម្បីការពារខ្លួនពីការផ្តន្ទាទោសដូចតំណាងរាស្រ្តដែរ ប៉ុន្តែលក្ខខណ្ឌនេះត្រូវបានគណបក្សទាំងពីរច្រានចោលនៅក្នុងការធ្វើសេចក្តីព្រាងច្បាប់បោះឆ្នោតថ្មី។

ទោះជាយ៉ាងណាមន្ត្រីមកពីគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិបានរាប់បញ្ចូលបទប្បញ្ញត្តិមួយដែលតម្រូវឱ្យសមាជិក គ.ជ.ប. បោះបង់សញ្ជាតិបរទេសចោលដែលបានតម្រូវឱ្យលោកស្រី ពុង ឈីវកេក បោះបង់លិខិតឆ្លងដែនបារាំង និងកាណាដារបស់លោកស្រី។

សេចក្តីថ្លែងការណ៍របស់លោកស្រី ពុង ឈីវកេក បានបញ្ជាក់យ៉ាងច្បាស់ថា ក្តីរំពឹងដែលលោកស្រីចង់បានជាលក្ខខណ្ឌនៃការទទួលយកមុខតំណែងនេះ មិនត្រូវបានអនុវត្តតាមឡើយនៅក្នុងការធ្វើសេចក្តីព្រាងច្បាប់។

លោកស្រីបានសរសេរថា "នៅខណៈនោះតួនាទីសមាជិកទី៩សម្រាប់ខ្ញុំ គឺជាសមាជិកឯករាជ្យម្នាក់ពិតជានឹងរួមវិភាគទានយ៉ាងសំខាន់ដល់អព្យាក្រឹតភាពនៃស្ថាប័នរៀបចំការបោះឆ្នោតដើម្បីសម្រេចបេសកកម្មរបស់ខ្លួនស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន។ រហូតមកទល់ថ្ងៃនេះ រូបខ្ញុំជឿជាក់ថា មុខតំណែងមួយនេះ ខ្ញុំមិនអាចអនុវត្តទៅរួចនោះទេ"។

លោក គល់ បញ្ញា នាយកប្រតិបត្តិនៃគណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា ហៅកាត់ថា ខុមហ្វ្រែល បានមានប្រសាសន៍ថា ការសម្រេចចិត្តរបស់លោកស្រី ពុង ឈីវកេក គឺអាចយល់បានថា ដោយសារតែការខ្វះចន្លោះនៃច្បាប់ថ្មីទាំងនេះ។

លោកបានមានប្រសាសន៍ទៀតថា "ខ្ញុំយល់ពីអារម្មណ៍របស់គាត់ និងហានិភ័យខ្ពស់ពាក់ព័ន្ធនឹងច្បាប់ថ្មីស្តីពីគ.ជ.ប. និងស្តីពីការបោះឆ្នោតសភាជាមួយនឹងបទប្បញ្ញត្តិដែលគ្មានភាពវិជ្ជមានមិនធានាសេរីភាពនៃការបោះឆ្នោតលើកក្រោយៗ ហើយវានឹងដាក់បន្ទុកធ្ងន់លើ គ.ជ.ប."។

ប៉ុន្តែលោកបានអបអរសាទរចំពោះការជ្រើសរើសលោក ហង្ស ពុទ្ធា ដែលអង្គការមិនមែនរដ្ឋាភិបាលរបស់លោកគឺជាផ្នែកមួយនៃសម្ព័ន្ធភាពកំណែទម្រង់ការបោះឆ្នោត (ERA) ដែលមានលោក គល់ បញ្ញា ជាប្រធាន។

លោក គល់ បញ្ញា បានមានប្រសាសន៍បន្ថែមទៀតថា "ខ្ញុំមានក្តីរីករាយជាខ្លាំង ពីព្រោះគាត់ក៏ជាសមាជិករបស់ ERA ដែរ។ គាត់មានបទពិសោធន៍ខាងតស៊ូប្រយុទ្ធប្រឆាំងដើម្បីកំណែទម្រង់បោះឆ្នោត ហើយពេលនេះស្ថិតនៅក្នុងមុខតំណែងធ្វើសេចក្តីសម្រេចចិត្ត និងបំពេញការងារស្រាប់។ ខ្ញុំនឹងរក្សាទំនាក់ទំនងជាមួយគាត់ ដើម្បីឱ្យគាត់បន្តធ្វើកំណែទម្រង់ ទោះបីជាមានបញ្ហាទាំងអស់នេះនៅក្នុងច្បាប់នេះក៏ដោយ។ ខ្ញុំនៅតែសង្ឃឹមថា គ.ជ.ប.ថ្មី អាចដើរក្នុងទិសដៅត្រឹមត្រូវ ហើយផ្តល់ការបោះឆ្នោតកាន់តែប្រសើរ"៕

**សុខុម (រាយការណ៍បន្ថែមដោយ Colin Meyn)**

តមកពីទំព័រទី ១៤

## អង្គការសហប្រជាជាតិតែងតាំង...

បើទោះជាលោក ស៊ូបេឌី មានទំនាក់ទំនងមិនសូវល្អជាមួយរដ្ឋាភិបាលក៏ដោយក៏លោកតែងតែធ្វើរបាយការណ៍ជាទៀងទាត់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សស្តីពីចំណុចខ្វះខាតក្នុងប្រទេសកម្ពុជាដែរ ដែលជារឿយៗត្រូវបានរិះគន់ និងច្រានចោលដោយមន្ត្រីកម្ពុជា។

លោក ផៃ ស៊ីផាន អ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រីបានមានប្រសាសន៍កាលពីម្សិលមិញថា លោកស្រី ស្មីត ក៏ត្រូវការការយល់ព្រមពីក្រសួងការបរទេសផងដែរ ដែលមិនអាចទាក់ទងបាន។

លោក ផៃ ស៊ីផាន បានមានប្រសាសន៍ថា អ្នកធ្វើរបាយការណ៍មុនមិនបានជោគជ័យទេ ក្នុងតួនាទីនេះ "ពីព្រោះអ្នកទាំងនេះមិនយល់ច្បាស់ពីវប្បធម៌កម្ពុជានិងការប្រព្រឹត្តរបស់ប្រជាជនកម្ពុជា" ហើយបានចោទប្រកាន់ពួកគេថា បានប្រព្រឹត្តមកលើប្រទេសកម្ពុជាដូចជាសិស្សម្នាក់។

លោកបានមានប្រសាសន៍ថា "យើងជាប្រទេសមួយយើងមិនមែនជាថ្នាក់រៀនទេ"។ លោកបានបន្ថែមថា ប្រសិនបើលោកស្រី ស្មីត ត្រូវបានអនុម័តយល់ព្រមដោយរដ្ឋាភិបាលយើង រំពឹងថា ដៃគូថ្មីនេះនឹងជាដៃគូដ៏ល្អម្នាក់ ហើយយល់ដឹងពីវប្បធម៌កម្ពុជា"៕ **សារុន**


MARCOTTE LAW FIRM
ក្រុមហ៊ុនមេធាវី Marcotte
45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229

- សេចក្តីអន្តរាយដល់បុគ្គល
- សំណងបុគ្គល
- ពិការភាពដោយសន្តិសុខសង្គម
- បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
- ច្បាប់គ្រួសារ និងផែនការអចលនទ្រព្យ
- បណ្តឹងវិវាទទូទៅ
- ច្បាប់ធានារ៉ាប់រង
- ការរំលោភបទព្រហ្មទណ្ឌ
- គ្រោះថ្នាក់ចរាចរណ៍
- គ្រោះថ្នាក់នៅការដ្ឋាន
- បំណុលអចលទ្រព្យ
- បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍

មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទមកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ
(978) 458-1229
www.marcottelawfirm.com

Continued from page 06

## Request to Nullify Sister-City...

are very powerful and a much-feared force. He is arrogant and speaks like a thug, including his infamous warning to his critics and dissenters a few years ago, "I will close the door and beat the dog." Most scholars, historians, political experts and some world leaders know that he runs Cambodia like the mafia. He uses courts to intimidate and silence the media, NGOs, union leaders, environmentalists and opposition activists. Those who were perceived to be out of line by this regime were harassed and murdered, but the real perpetrators connected to his family and his Cambodian People Party (CPP) have not been brought to justice.

Mr. Hun Sen is desperate to make his democracy appear legitimate to the rest of the world. Any ties he can make with the West, especially with the United States, will undoubtedly be used as a PR stunt to justify his violent actions. The sister-city agreement with Lowell will be added to his arsenal of political weapons to be used against the people of Cambodia. This agreement will also serve as the conduit which the CPP will use to extend their political ideology to influence the hearts and minds of the Cambodian-American here in Lowell.

As Lowell residents, we would love to see our city have a healthy relationship with Phnom Penh. However, we do not believe Mr. Hun Sen will use the Mill City's influence to benefit the poor people of Cambodia. We collectively, as residents of Lowell, ask you and your colleagues to reconsider your position on this matter and to nullify this agreement.

We thank you for your time and consideration regarding this very important issue.

Sincerely,

Representatives of Concerned Residents

-Matinol Chan
- Chinda Kruth
- Timothy S Mouth
- Bopha Peou
- Thara Ros
-Thel Sar
- Keto Tan
- Chhan Touch
-Vathana Ven

CC: - City Councilors
- City Manager Kevin J. Murphy

SAVINGS WITH MASS APPEAL

DRIVERS WHO SWITCHED SAVED

$498

NATIONAL ANNUAL AVERAGE

**Want to save on car insurance? Call me first.**

It's time Massachusetts drivers had a better car insurance experience. I'll help you get the coverage that's right for you and the discounts you deserve. Call me today.



**Vanessa Dinh**
**781-547-6522**
665 Main Street
Waltham
vanessadinh@allstate.com

Allstate.
You're in good hands.

Savings based on national customer-reported data for new policies in 2012. Actual savings vary. Allstate Insurance Co. Northbrook, IL. © 2013 Allstate Insurance Co.

AccuCare
Home Care Agency
Group Adults Foster Care Program

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

Homecare Agency
Group Adult Foster Care Program (GAFC)
MassHealth

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្ដានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ



*Compassionate Care & Reliable*
*Professional & Cultural Sensitive*
*Management & Staffs speak Khmer*

*កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើង ដែលមានប ញ្ហារាំរ៉ៃផែកសុខភាព ឬជរាហើយមិនចង់ ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្ដល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្ដង ។*

*Accucare Homecare Agency is the perfect solution for seniors and others who are not ready to leave their home for an institutional setting or live with reltives because of illness or chronic conditions. We improve your life by providing one-on-one compassionate senior care in the comfort of your own home.*

*ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :*
*To be eligibled for GAFC you must:*
*-រស់នៅផ្ទះរដ្ឋ (live in subsidized or public housing)*
*-អាយុ ២២ ឆ្នាំឡើងទៅ (age 22 years and older)*
*-មាស់ហែលស្ទង់ដា (eligible for Masshealth Standard)*
*-ត្រូវការជំនួយក្នុងការរស់នៅប្រចាំថ្ងៃយ៉ាងហោចណាស់មួយដូចជា មុជទឹក ស្លៀក-ពាក់ ពេលប្រើបន្ទប់ទឹក ចំអិនអាហារ ឬ ពេលដើរ (need daily assistance with one or more personal care tasks such as bathing, dressing, toileting, meal preparation and/or moving)*
*-មានការអនុញ្ញាតពីគ្រូពេទ្យផ្ទាល់ខ្លួនអ្នក (have physician statement of your condition)*
*-ត្រូវបានវាយតំលៃផ្នែកសុខភាព និងការអនុម័តយល់ព្រមពីកម្មវិធី (be screened and approved for the program )*

*ផលប្រយោជន៍ទទួលបាន :*
*Benefits you will get:*
*-ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ (personal care service in your home, up to one hour of service each day)*
*-ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក (Medication Managemant)*
*-ផែនការថែរទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីជើ (an individual care plan developed by a registered nurse and case manager)*
*-វាយតំលៃលើសេចក្ដីត្រូវការជាប្រចាំជាបន្តបន្ទាប់ (ongoing monitoring of needs)*
*-សមាជិកអាចទាក់ទងមក ២៤ម៉ោង (24-hour access to services)*

**ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston**

ដើម្បីចុះឈ្មោះសូមទាក់ទងមក
To register, please contact:

ឱក តុលាយុត្តិ ឡូវែល
Tolayuth Ok: Lowell
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

## តមកពីទំព័រទី ០៤ ការបោះឆ្នោតនៅវត្តត្រៃរតនារាម...

នៅពេលពួកគាត់ចែកឋាន។ ខ្ញុំនឹងខិតខំប្រឹងប្រែងកសាងសាសនាយើងឱ្យរីកចម្រើន"។

ជាចុងបញ្ចប់លោក រិទ្ធី អ៊ុង បានលើកឡើងអំពីការបោះឆ្នោតនេះថា "យើងមានក្រដាសពីតុលាការត្រឹមត្រូវក្នុងការសម្រេចអនុញ្ញាតឱ្យរៀបចំការបោះឆ្នោតនេះ -ដូច្នេះការនិយាយចោទប្រកាន់ណាមួយថា ការបោះឆ្នោតនេះមិនត្រឹមត្រូវគឺជាការចោទប្រកាន់គ្មានមូលដ្ឋាន"។ លោក រិទ្ធី អះអាងបន្តថា "ការបោះឆ្នោតថ្ងៃនេះ គឺជារៀបចំត្រឹមត្រូវតាមសេចក្តីសម្រេចតុលាការកំពូល ដើម្បីបញ្ចប់វិវាទ និងជម្លោះនៅវត្តនេះ -ដូច្នេះចាប់ពីថ្ងៃនេះតទៅគ្មានទៀតទេវត្តលើវត្តក្រោម -គឺមានតែវត្តតែមួយ"៕


ប្រធានថ្មី អ៊ិវិន ធីម ជំនួសប្រធាន ប្រាហ៊ីម កែ




លោក ជា តែម គណកម្មការបោះឆ្នោត


**KhmerPost USA, LLC**
សារពត៌មានខ្មែរផុសសហរដ្ឋអាមេរិក

អាស័យដ្ឋាន 45 Merrimack St. Suite 218A. Lowell, MA 01852
លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092
អ៊ីម៉ែល info@khmerpost.us
អានកាសែតនៅគេហទំព័រ www.khmerpost.us
តាមដានយើងនៅទំព័រហ្វេសប៊ុក Like us at: www.facebook.com/KhmerPostUSA

ផ្សាយពាណិជ្ជកម្ម **Advertising**
អគ្គនាយកទីផ្សារ និងគ្រប់គ្រង សុបិន្ត ពិន Soben Pin, *Managing Partner*
លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office)
អ៊ីម៉ែលsobenpin@khmerpost.us

អ្នកនិពន្ធ **Editorials**
និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Publisher & Editor-in-Chief*
(978) 942 - 1641 | rogerpin@khmerpost.us

អ្នកនិពន្ធកិត្តិយស **Contributed Writers:**
Kim Phien, Richard Howe,Jr.

ច្នៃសោភ័ណភាពកាសែត **Design Artist**
Heng Chhunleng
នាយករដ្ឋបាល Office Manager **978-677-7163**
Thach Vanna ថាច់ វណ្ណា

KhmerPost USA, LLC is an independent newspaper that aims to facilitate mass communication among the Cambodian communities, their neighboring communities, and families. We aim to address local community, and national news; and give an insight into Cambodian & global news. We also strive to bridge the language and cultural gaps and reduce social isolation by publishing in Khmer & English. It published twice a month in Massachusetts serving Greater Lowell, Lynn, Revere, MA, Providence, RI, CT, NY, NJ, and Philadelphia, PA.

Mail subscription is available within the U.S. & Canada at 100.00 or 120 Euros in Europe per year.

The KhmerPost USA has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009





# ហាងខ្មែរជួសជុលរថយន្ត

**បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ**

# Rathe´s Auto Service

State and Emission Inspaction General Repairs and Maintenance

MON-SAT, 8:30AM-5:30PM
SUN. EMERGENCY ONLY




- ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
- មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
- មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ
- មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : - ដូរប្រេងកំរិត ៥ ក្វាត $22
- INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់ -មានជូនប័ណ្ណពិសេសសំរាប់ដូរប្រេងចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
- តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត ។
- ប្តេជាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ។ ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL : (215) 329-2418
Fax : (215) 329-2419. Rath CELL : (215) 431-6376

# ANGKOR AUTO SERVICE,INC.

# ហាងជួសជុលរថយន្ត "អង្គរ"

**Free Estimate**

**Auto Body and Maintenance**



**BODY WORKS**
Auto glass and windshields
Auto Frame Straightening and Painting

មានបទពិសោធន៍២០ឆ្នាំ ជាជាងរថយន្តមានសញ្ញាប័ត្រវាយតម្លៃការងារដោយឥតយកថ្លៃ ហើយយើងជួយសន្សំប្រាក់តម្លៃបន្ថយរបស់អិនស្វ៊ិរិនបានផង យើងផ្តល់សេវាគ្រប់យ៉ាង :

ENGINE AND TRANSIMISSION SERVICES
State Inspection
Check Engine Light Diagnostic
Timing Belt Services
Complete Tune Up:
-Brake -Muffler -Struts
-Water Pump -A/C
-Bearing Services



From the moment you get into car accident, we will take care of you from towing to calling your insurance, and to get a rental car for you. With Angkor Auto, you can be worried free.

4835 N. 16th Street. Philadelphia, PA 19141
Tel : (215) 455-7810 / Ricky : (215) 485-1425


ពិធីបុណ្យចូលឆ្នាំខ្មែរ
ឆ្នាំមមែ ព.ស.២៥៥៩ គ.ស.2015
YEAR OF THE GOAT
CAMBODIAN NEW YEAR CELEBRATION
FREE EVENT
Saturday April 11, 2015 12pm - 5pm
Pailin Volleyball Complex at Clemente Park
803 Middlesex St., Lowell, MA 01851
You are invited to celebrate the Cambodian New Year at Clemente Park!
តាងនាមគណៈកម្មការរៀបចំពិធីបុណ្យចូលឆ្នាំខ្មែរ យើងខ្ញុំមានកិត្តិយស សូមអញ្ជើញបងប្អូនរួមជាតិខ្មែរទាំងអស់ មកចូលរួមក្នុងពិធីបុណ្យចូលឆ្នាំខ្មែរ នៅសួនប៉ៃលិន ដើម្បីរីករាយកំសាន្តជាមួយតន្ត្រីសម័យ បុរាណ ទស្សនា របាំ និងលេងល្បែងប្រជាប្រិយខ្មែរ មានចោលឈូង បោះ អង្គុញ លាក់កន្សែងជាដើម។ នេះជាឱកាសដ៏ល្អមួយសំរាប់បង្ហាញឲ្យកូនខ្មែរជំនាន់ក្រោយស្គាល់ពីទំនៀមទំលាប់ សិល្បៈវប្បធម៌ខ្មែរ និងរួមគ្នាថែរក្សាអត្តសញ្ញាណជាតិយើងឲ្យបានគង់វង្ស ។
Featuring:
Khmer Live Band • Cultural Dances
Traditional Khmer Music • Folk Games
Special Appearance by Chuck E. Cheese!
This is a free event put together by the Clemente Park Committee, Cambodian Town Committee, and volunteers.
We would like to wish you a Happy New Year, the Year of the Goat!
To Volunteer, Email: volunteer.clementepark@gmail.com
For more information, visit us at:
www.facebook.com/clementeparkcommittee
www.facebook.com/cambodiatownlowell
CAMBODIA TOWN
LOWELL POLICE MA
KHMER CULTURAL COUNCIL
KhmerPost USA
LTC ORG
CHUCK E. CHEESE'S

តមកពីទំព័រទី ១៩

## អាមេរិកមានប្រសាសន៍ថា ការអប់រំ...

លើអំណាចនៃការអប់រំដើម្បីជម្នះបញ្ហាទាំងនោះ និងអាចឱ្យអ្នករិះគន់រដ្ឋាភិបាលស្ងប់ចិត្តដោយបង្ហាញភាពស្និទ្ធស្នាលជាមួយលោកស្រី ប៊ុន រ៉ានី ភរិយារបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន។

លោកស្រី អូបាម៉ា បានប្រាប់មេដឹកនាំសង្គមស៊ីវិលអ្នកមុខអ្នកការ និងអ្នកស្ម័គ្រចិត្ត Peace Corps ពេញមួយបន្ទប់ អំឡុងការថ្លែងសុន្ទរកថាកាលពីថ្ងៃសៅរ៍នៅសណ្ឋាគារសូហ្វីតែល អង្គរ ភូគិត្រា ថា "ពេលដែលក្មេងស្រីទទួលបានការអប់រំនិងពេលដែលពួកគេរៀនអាន សរសេរ និងគិតទាំងនេះផ្តល់ឱ្យពួកគេនូវចំណេះឱ្យហ៊ាននិយាយ និងវែកញែកអំពីអយុត្តិធម៌ និងទាមទារឱ្យមានការយកចិត្តទុកដាក់ស្មើភាពគ្នា។ វាជួយពួកគេឱ្យចូលរួមក្នុងជីវភាពនយោបាយនៃប្រទេសរបស់ខ្លួន និងឱ្យមេដឹកនាំរបស់ខ្លួនមានការទទួលខុសត្រូវ"។

ស្ត្រីទី១រូបនេះមានគម្រោងដ៏មមាញឹកកាលពីថ្ងៃសៅរ៍ដែលបានចាប់ផ្តើមការធ្វើទស្សនកិច្ចមួយរួមជាមួយលោកស្រី រ៉ានី ទៅសាលារៀនមួយកន្លែងដែលនៅទីនោះលោកស្រីបាននិយាយទៅកាន់សិស្សដែលចូលរៀនក្នុងកម្មវិធីគំនិតផ្តួចផ្តើមរបស់អង្គការរ៉ូមធូរីដដែលដឹកនាំដោយអាមេរិកផងដែរ។

លោកស្រី អូបាម៉ា បានចែករំលែកការយល់ឃើញរបស់លោកស្រីពីការធ្វើទស្សនកិច្ចក្នុងទស្សនាវដ្តីដំណើរតាមអ៊ីនធឺណិតដោយបានរៀបរាប់រឿងជាច្រើនដែលប្រាប់ដោយសិស្សពីរនាក់ដែលលោកស្រីបានជួប គឺសិស្សឈ្មោះ សុហាង វៀន និង ឡន ភូណាំ។

លោកស្រីបានសរសេរថា "ខ្ញុំមានសេចក្តីរីករាយដោយបានជួបជាមួយក្មេងស្រីទាំងនេះ ហើយពួកគេល្អណាស់ ត្រេកអរចង់រៀនសូត្រណាស់ និងតាំងចិត្តបន្តការសិក្សាដើម្បីសម្រេចសុបិនរបស់ខ្លួន"។

ជិតអធ្រាត្រទៅហើយពេលដែលស្ត្រីទី១បានត្រឡប់ទៅសណ្ឋាគារសូហ្វីតែលដើម្បីថ្លែងសន្ទរកថា ដោយថ្លែងទៅកាន់អ្នកស្ម័គ្រចិត្តដែលនឹងអនុវត្តកម្មវិធីឱ្យក្មេងស្រីរៀន រួមជាមួយមេដឹកនាំសហគមន៍ក្មេងៗ និងសកម្មជននៅមូលដ្ឋាន។

អ្នកយកព័ត៌មានភាគច្រើនដែលបានធ្វើដំណើរទៅកាន់ខេត្តសៀមរាប ដើម្បីរាយការណ៍អំពីដំណើរទស្សនកិច្ចរបស់លោកស្រីអូបាម៉ា បានខកចិត្តត្រូវអង្គុយរង់ចាំនៅឯសណ្ឋាគារសូហ្វីតែល ខណៈដែលស្ថានទូតអាមេរិកជ្រើសយកអ្នកកាសែតតែមួយចំនួនប៉ុណ្ណោះ ដើម្បីរួមដំណើរជាមួយក្បួនរថយន្តរបស់ស្ត្រីទី១ ដែលចាកចេញដំណើរទៅមើលទេសភាពអង្គរវត្តនាពេលសៀល។

លោក ជេ រ៉ាម៉ាន អ្នកនាំពាក្យស្ថានទូតអាមេរិកបានមានប្រសាសន៍ថា អ្នកកាសែតមួយក្រុមតូចត្រូវបានផ្តល់អាទិភាព។

លោក រ៉ាម៉ាន បានឱ្យដឹងតាមរយៈសារអេឡិចត្រូនិចថា "ដោយសារកន្លែងមានកម្រិតក្នុងក្រុមក្នុងការធ្វើដំណើររួមគ្នាយើងត្រូវជ្រើសរើសការផ្សំគ្នានៃបណ្តាញព័ត៌មានដែលល្អបំផុតអាចជួយយើងពាំនាំសារនៃដំណើរទស្សនកិច្ចរបស់ស្ត្រីទី១ដល់អ្នកស្តាប់ដ៏ច្រើន។ តែគួរឱ្យស្តាយយើងមិនអាចទទួលយកបានគ្រប់គ្នាទេ"។

នៅពេលដែលស្ត្រីទី១មិនបានឆ្លើយតបនឹងបញ្ហារសើបណាមួយដោយផ្ទាល់លោកស្រីបានប្រើសុន្ទរកថារបស់លោកស្រីពន្យល់ថាតើការអប់រំអាចផ្តល់អំណាចដល់មនុស្សដើម្បីប្រឆាំងយ៉ាងសកម្មនឹងអសមភាពនិងភាពអយុត្តិធម៌បែបណា។ លោកស្រី អូបាម៉ា ក៏បានពណ៌នាអំពីលោកស្រីខ្លួនឯងផ្ទាល់បានជម្នះការលំបាកជាច្រើនតាមរយៈការខិតខំធ្វើការនិងការតាំងចិត្តជាប្រធានបទមួយដែលមានឥទ្ធិពលយ៉ាងច្បាស់លើអ្នកស្តាប់របស់លោកស្រី។

លោកស្រី ប៉ោ ឡាយហៀង គ្រូបង្រៀនអាយុ២៧ឆ្នាំមកពីខេត្តកំពង់ធំ ដែលបានបង្រៀនភាសាខ្មែរដល់អ្នកស្ម័គ្រចិត្ត Peace Corps រយៈពេលបួនឆ្នាំកន្លងមកនេះ បានមានប្រសាសន៍ថា លោកស្រីសប្បាយរីករាយដែលស្ត្រីទី១បានផ្តោតការយកចិត្តទុកដាក់ខ្លាំងលើសារៈសំខាន់នៃការអប់រំសម្រាប់ក្មេងស្រី។

លោកស្រីមានប្រសាសន៍ថា "មានក្មេងស្រីច្រើនទៀតស្ថិតក្នុងការសិក្សា ប៉ុន្តែពេលដែលពួកគេរៀនដល់ថ្នាក់វិទ្យាល័យ ពួកគេត្រូវគ្រួសារបង្ខំឱ្យឈប់រៀនដើម្បីជួយបងប្រុសឬបងស្រីឱ្យបានរៀននៅសាកលវិទ្យាល័យ នេះមិនមែនស្ថានភាពល្អសម្រាប់ស្ត្រីកម្ពុជាទេ"។

លោកស្រី អូបាម៉ា ដែលគេច្រើនតែហៅថា FLOTUS មានន័យថាស្ត្រីទី១ នៃសហរដ្ឋអាមេរិក បានមានប្រសាសន៍គ្រប់គ្រាន់ក្នុងសុន្ទរកថារបស់លោកស្រី ដើម្បីឆ្លើយតបនឹងលោក ហ្វិល រ៉ូប៊ឺតសុន នាយករងអង្គការឃ្លាំមើលសិទ្ធិមនុស្សនៅអាស៊ី Human Rights Watch ដែលបានប្រើបណ្តាញសង្គមធ្វីតធីស្នើឱ្យលោក អូបាម៉ា អនុវត្តតាមការងារមូលដ្ឋានរបស់ភរិយាលោក។

លោកបានសរសេរថា "ល្អ! @FLOTUS បានលើកឡើងអំពីបញ្ហាសិទ្ធិនៅក្នុងប្រទេសខ្មែរ ឥឡូវដល់ពេលស្វាមី គឺ បារ៉ាក់ អូបាម៉ា អនុវត្តតាមគោលការណ៍ចម្បងទាំងនេះ"។

ប៉ុន្តែសកម្មជនលំនៅដ្ឋានជាង១០០នាក់មកពីសហគមន៍នានាដែលបានមកជួបជុំគ្នានៅខាងក្រៅស្ថានទូតអាមេរិកកាលពីព្រឹកថ្ងៃសៅរ៍សង្ឃឹមថា នឹងមានរបៀបដោះស្រាយផ្ទាល់ដើម្បីឱ្យមានការដោះលែងសកម្មជនស្ត្រី១០នាក់ដែលជាប់ពន្ធនាគារពីបទចោទទាក់ទងនឹងការតវ៉ាកាលពីឆ្នាំមុន។

ប៊ូវ សោភា តំណាងសហគមន៍បឹងកក់ដែលទទួលរងការបណ្តេញចេញបាននិយាយថា "យើងជឿថា លោកស្រីនឹងលើកបញ្ហានេះឡើងជាមួយរដ្ឋាភិបាលកម្ពុជា ពីព្រោះយើងបានឮថា លោកស្រីបានលើកបញ្ហាជាច្រើនទាក់ទិននឹងសិទ្ធិរបស់ស្ត្រី។ លោកស្រីអាចប្រើឱកាសនេះដើម្បីលើកកម្ពស់សិទ្ធិរបស់ស្ត្រី"។

មុនពេលលោកស្រីចាកចេញលោកស្រីអូបាម៉ា បានមានប្រសាសន៍ក្នុងសុន្ទរកថា របស់លោកស្រីនៅសណ្ឋាគារសូហ្វីតែលថា លោកស្រីសង្ឃឹមថា សាររបស់លោកស្រី និងគំនិតផ្តួចផ្តើមឱ្យក្មេងស្រីរៀនអាចជាមូលដ្ឋានគ្រឹះឋិតថេរសម្រាប់ក្មេងស្រីក្នុងប្រទេសនេះ។

លោកស្រីបានមានប្រសាសន៍ថា "លោកអ្នកទាំងអស់គ្នាកំពុងខិតខំធ្វើការឱ្យមានការផ្លាស់ប្តូរ ហើយលោកអ្នកគួរមានមោទនភាពអំពីខ្លួនឯង។ ដូច្នេះសូមបន្តទៀត...សន្យា?"។

**និត (រាយការណ៍បន្ថែមដោយ មិច ដារ៉ា)**

Continued from page 17

## Preah Buddha Rangsey Temple...

know best with one another, they are both working at their actual level of intellectual maturity.

Educational: Students who learn English and continue to develop their native language have higher academic achievement in later years than do students who learn English at the expense of their first language.

Economic: Better employment opportunities in this country and overseas are available for individuals who are fluent in English and another language.

Khmer Class open at the Cambodian Temple every Sunday at 1:30 pm !!! Please walk in or call: (215) 939-9968 for more information.

តមកពីទំព័រទី ១៩

## និពន្ធនាយក...

នៅកាសែតដែលគ្រប់គ្រងដោយរដ្ឋមួយចំនួនក្នុងរដ្ឋធានី។

អំឡុងនយោបាយសង្គ្រាមត្រជាក់នៅពេលនោះ លោក ប៉ែន សមិទ្ធិ បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រខាងវិទ្យាសាស្ត្រនយោបាយក្នុងឆ្នាំ១៩៨៦ ពីសាកលវិទ្យាល័យមួយក្នុងប្រទេសវៀតណាម ហើយក្នុងឆ្នាំ១៩៨៧ លោកទទួលបានបរិញ្ញាបត្រផ្នែកសារព័ត៌មាននៅសហភាពសូវៀត។

ងាកមកការងារជាអ្នកនិពន្ធក្នុងរាជធានីភ្នំពេញឯណោះវិញ លោក ប៉ែន សមិទ្ធិ កាលពីខែមេសា ឆ្នាំ១៩៩៣ បានក្លាយជានិពន្ធនាយកកាសែតរស្មីកម្ពុជាដែលជាកាសែតប្រចាំថ្ងៃដ៏មានអ្នកអានច្រើនបំផុតក្នុងប្រទេសកម្ពុជា។

លោក ប៉ែន សមិទ្ធិ បានកាន់តួនាទីនេះរហូតដល់ពេលលោកស្លាប់ទន្ទឹមនឹងនោះដែរលោកក៏បានក្លាយជាប្រធានក្លឹបអ្នកកាសែតកម្ពុជាក្នុងឆ្នាំ២០០០ ហើយបានបង្កើតគេហទំព័រ Cambodia Express News ក្នុងឆ្នាំ២០០៨។

លោក ងួន សេរ័ត្ន សហសេវិករបស់លោកបានមានប្រសាសន៍ថា ពិធីបុណ្យសពដែលបានចាប់ផ្តើមកាលពីម្សិលមិញនឹងបញ្ចប់នៅថ្ងៃព្រហស្បតិ៍មុនពេលសពរបស់អ្នកកាសែតរូបនេះនឹងត្រូវបូជានៅវត្តលង្កាក្នុងរាជធានីភ្នំពេញ។ លោក ប៉ែន សមិទ្ធិ បានស្លាប់ចោលប្រពន្ធ កូនស្រីម្នាក់ និងកូនប្រុសម្នាក់៕ **សារុន**

តមកពីទំព័រទី ០២

## ព្រះអង្គម្ចាស់ធម្មិកោ...

ម្ល៉ោះហើយអ្នកទាំងនោះឯងជាអ្នកចាប់ផ្តើមកម្ចាត់យួនក្នុងជួរកងទ័ពជួរក្រសួង។ អ្នកទាំងអស់នោះឯងជាអ្នករើបម្រះមុនយើងទៅទៀត។ គេចាំតែសង្គ្រោះជាតិឈ្នះ ដើម្បីចាត់វិធានការ។

ពេលគណបក្សសង្គ្រោះជាតិឈ្នះឆ្នោតយើងអាចកាត់បន្ថយអំពើពុករលួយបានតាមរយៈការយកច្បាប់មកអនុវត្ត។ ច្បាប់អាក្រក់យើងយកមកកែឱ្យល្អ។ យើងនឹងយកសាសនាមកធ្វើជាមូលដ្ឋាន ដើម្បីស្តារសីលធម៌ គុណធម៌ សច្ចធម៌ ដែលឈរលើសាសនា ប៉ុន្តែត្រូវបានយួនបំផ្លាញនៅស្រុកខ្មែរយើងដែលធ្វើឱ្យកើតអំពើពុករលួយពេញផ្ទៃប្រទេស ។ សង្គ្រោះជាតិមានយុទ្ធសាស្ត្រ ដើម្បីដឹកនាំប្រទេសមិនមែនត្រឹមតែដឹកនាំបក្សទេ។ យើងមើលគំរូប្រទេសឥណ្ឌូនេស៊ី។ របបស៊ូ ហាតូ និងរបបកម្ពុជាបច្ចុប្បន្នមានរចនាសម្ព័ន្ធពុករលួយ និងការរំលោភអំណាចដូចគ្នា។ សង្គ្រោះជាតិនឹងរៀបចំដំណើររបស់ខ្លួនឱ្យដូចអ្វីដែលមាននៅឥណ្ឌូនេស៊ីដោយមិនបង្ហូរឈាម។ ចៀសវាងកុំឱ្យបង្ហូរឈាមខ្មែរលើដីខ្មែរ"។

ព្រះអង្គម្ចាស់ ធម្មិកោជាបេក្ខជនគណបក្សសង្គ្រោះជាតិនៅតំបន់ខេត្តព្រះសីហនុដែលមានអសនៈពាកន្លែង៕

Continued from page 09

## Senior military and police officers

is the oldest active-duty infantry regiment in the U.S. Army, serving our nation since 1784. "America's Army" will tell a story about America's history, beginning with the Revolutionary War era to the present day, with military music and a proud narrative inspired by the patriotism that fueled the heroic acts celebrated during Patriots Day.

Monday, April 20th, 5:30am
Lexington Battle Reenactment
Lexington Green

The Town of Lexington celebrates the first shots of the American Revolution with a reenactment of the early-morning engagement between the town's militia and the British regulars.

Monday, April 20th, 8:45am
Commemoration of the North Bridge Fight and Concord Parade
North Bridge, Concord

British reenactors will be joined by the Acton Minutemen and other local companies for a special commemoration of the North Bridge Fight featuring musket volleys. The Concord Parade will arrive at North Bridge around 9:30 a.m. NOTE: All of the roads in the center of town are closed to vehicles beginning at 8:30 a.m.

**Liberty Ride**
Weekends through May 24, 2015
www.libertyride.us

Visit the birthplaces of American liberty and 19th century literature! Board a classic trolley to ride along the historic Battle Road while your costumed guide recounts the exciting events of April 19, 1775 and the literary legacy that defined American identity and culture. (fee)

For more information on the week long activities visit www.battleroad.org

## តមកពីទំព័រទី ០៩ អំពីទីក្រុងនៅតំបន់...

ការរម្លឹកការចងចាំនៃព្រឹត្តិការណ៍ប្រយុទ្ធគ្នានៅ North Bridge និងក្បួនដង្ហែរនៅ Concord North Bridge, Concord ក្រុមដែលសម្តែងតួអង្គជនជាតិអង់គ្លេស មានដូចជាក្រុមកងឈ្លប Acton Minutemen និងក្រុមហ៊ុនឯកជននៅមូលដ្ឋាន។ ក្រុមទាំងនេះ ចូលរួមក្នុងកម្មវិធីរម្លឹកការចងចាំនៃព្រឹត្តិការណ៍ប្រយុទ្ធគ្នានៅ North Bridg ដោយមានបាញ់កាំភ្លើងវែង។ ក្បួនដង្ហែរ the Concord Parade នឹងទៅដល់ North Bridge នៅវេលាម៉ោង៩ និង៣០នាទីព្រឹក។

**កំណត់ចំណាំ:** ផ្លូវទាំងអស់នៅកណ្តាលទីក្រុងនឹងត្រូវបិទមិនឱ្យរថយន្តឆ្លងកាត់ ចាប់ពីម៉ោង៨ និង៣០នាទីព្រឹក។

ដំណើរកំសាន្តជិះតាមរទេះភ្លើង Liberty Ride នៅរាល់ថ្ងៃចុងសប្តាហ៍ រហូតដល់ថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០១៥
www.libertyride.us

សូមអញ្ជើញមកលេងទីកន្លែងកំណើតនៃ សេរីភាពរបស់ជនជាតិអាមេរិក និងអក្សរសាស្ត្រសតវត្សទី១៩របស់អាមេរិក! ជិះរទេះភ្លើងបុរាណ ដើម្បីមើលទេសភាពនៅតាមផ្លូវដែលជាអតីតសមរភូមិក្នុងប្រវត្តិសាស្ត្រ។ អ្នកនាំភ្ញៀវស្លៀកសម្លៀកបំពាក់បែបបុរាណ នឹងពន្យល់រៀបរាប់អំពីព្រឹត្តិការណ៍ដែលបានកើតឡើងនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៧៧៥ ព្រមទាំងកេរដំណែលអក្សរសាស្ត្រដែលកំណត់អត្តសញ្ញាណ និងវប្បធម៌អាមេរិក។ (ដំណើរកំសាន្តនេះត្រូវបង់ប្រាក់) អំពីព័ត៌មានបន្ថែមស្តីពីសកម្មភាពពេញមួយសប្តាហ៍ សូមបើកមើលគេហទំព័រ www.battleroad.org


# CLASSIFIED ADS

**CALL: 978.677.7163**

EMAIL: SOBENPIN@KHMERPOST.US

monroe STAFFING
I OF STAFFING 360 SOLUTIONS

### ក្រុមហ៊ុនរកការងារ Monroe

បានប្តូរមកនៅក្រុងឡូវែល សម្រាប់រកការងារជូនដល់លោកអ្នក ជាពិសេសផ្នែកឧស្សាហកម្មធុនស្រាល និងរោងចក្រផលិតកម្មក្នុងតំបន់ និងជុំវិញក្រុងឡូវែល -ម៉ូនរ៉ូ នឹងជួយផ្តល់ការងារ ផ្នែកប្រើម៉ាស៊ីន, ឈរជួរផលិត, ឃ្លាំងទំនិញ និងដំឡើងសង្វាក់ផលិតកម្មជាដើម។ សូមអញ្ជើញមកការិយាល័យយើងខ្ញុំនៅ លេខ៤០ Central St. Lowell, MA 01852, ដើម្បីធ្វើបែបបទ និងមានឱកាសជាច្រើនសម្រាប់រកការងារធ្វើ ៕

**Your classify ad is here for only $50 per month**

ពាណិជ្ជកម្មរបស់អ្នកនៅទីនេះ
ចំណាយចំណាយត្រឹមតែ
**$50** ក្នុង១ខែ

*CALL:*
*978.677.7163*
*EMAIL: SOBENPIN@KHMERPOST.US*

### សិក្សាពីឥស្លាម

**សួរ :** មានចម្ងល់អ្វីទេពីឥស្លាម?
**ឆ្លើយ :** សូមទៅមើលគេហទំព័រ www.peacetv.tv ឬគេហទំព័រមួយទៀត www.gainpeace.com.
Q) Any Questions on Islam?
A)watch www.peacetv.tv
visit www.gainpeace.com.

### ការិយាល័យ មេធាវី ថំមាស ស្តាលីយ៉ាណូស

**Law Office of Thomas Stylianos Jr.**
**287 Appleton St. Lowell MA 01852**

- Immigration • អន្តោប្រវេសន៍
- Auto Crash • គ្រោះថ្នាក់រថយន្ត
- Divorce • លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766

GREATER LOWELL
CHAMBER OF COMMERCE

131 Merrimack Street – Lowell MA
978-459-8154
www.greaterlowellchamber.org

**A resource for your business or organization!**
**សភាពាណិជ្ជកម្មនៅក្រុងឡូវែល គឺជាធនធានមួយសម្រាប់មុខរបរ ឬសម្រាប់អង្គការរបស់លោកអ្នក**

Networking Events — ព្រឹត្តិការណ៍ទំនាក់ទំនង
Seminars — សន្និសីទ
Resources — រកធនធាន
TV & Radio Shows — កម្មវិធីទូរទស្សន៍ និងវិទ្យុ
And more! — និងនៅមានច្រើនទៀត

# ប្រវត្តិសង្ខេប"ទឹកដីកម្ពុជាក្រោម"វគ្គទី២



ដោយ ថាច់ វណ្ណា

**បន្តការចុះផ្សាយ**

**លើកទី២:**

**ដោយ ថាច់ វណ្ណា**

តាមសៀវភៅ "ប្រវត្តិចៅហ្វាយគុយមុនឆ្នាំ១៩៧៥បានសរសេរថាៈ មុនកិច្ចចាររវាងមេទ័ពយួន,លោកចៅហ្វាយគុយបានធ្វើសំណើកុំឱ្យយួនកាត់ទោសត្រកូល

**ទាំង៤គឺ:** ថាច់,សិន,កៀន និងគីម (Thach, Son, Kien, Kim) ដែលជាត្រកូលមេទ័ពនឹងយោធា, នយោបាយ, សេដ្ឋកិច្ច ហិរញ្ញវត្ថុ, និងផ្នែករដ្ឋបាល ទើបព្រមទទួលកិច្ចចរចា,បើមិនច្នោះទេ ខ្មែរក្រោមទាំងអស់ស៊ូច្បាំងតទល់លុះគ្រាអវសានន្តនៃជីវិតទាំងអស់គ្នា, ទីបំផុត, យួនក៏បានយល់ព្រមតាមសំណើរបស់លោកចៅហ្វាយសឺនគុយកិច្ចចរចាក៏បានធ្វើឡើងនៅឆ្នាំ១៨៤១, រួចលោកឧកញ៉ា ក៏បានកាច់មែកឈើទាលដាំបញ្ច្រាស់ចុងចុះដី"បួល"ពាក្យផ្សងថាៈ "ពេលដែលខ្ញុំស្លាប់ទៅសូមព្រលឹងស្ថិតនូវថែរក្សាជាតិ និងសាសនាឱ្យបានគង់វង្ស រួចនិងសូមឱ្យដើមឈើទាលនេះរស់រៀនមានជីវិតតរៀងទៅ, បន្ទាប់មកយួនក៏បានកាត់ក្បាលលោកឧកញ៉ា សឺន គុយ ក្នុងពេលនោះឯង ។




នោះជាហេតុដ៏សែនអស្ចារ្យមានតែមួយគ្មានពីរនៅលើលោក, ព្រោះមែកឈើទាលគ្មានអ្នកណាម្នាក់អាចដាំបានរស់ឡើយ, រីឯដាំបញ្ច្រាស់យកចុងចុះដីវិញនោះ, ធ្វើឱ្យមានការស្ញប់ស្ញែងរកអ្វីប្រៀបផ្ទឹមពុំបាន ។(សូមអញ្ជើញរកមើលតាមអីន តើណែត Khmer krom National Soul's Tree) អស់លោកអ្នក និងបានឃើញដើមឈើនេះកំពុងមានជីវិតរស់នៅក្នុងស្រុកសំបួរ ខេត្តព្រះត្រពាំង កម្ពុជាក្រោម) ពាក្យបណ្តាំចុងក្រោយរបស់ឧកញ៉ា សឺន គុយ "ខ្ញុំ មានសេចក្តីរំភើបជាអនេកដោយបានជួបមុខព្រះសង្ឃ និងជនរួមជាតិទាំងអស់ក្នុងខណៈដែលខ្ញុំធ្វើពលីកម្មជីវិតនាពេលនេះ,សូមព្រះសង្ឃនិងជនរួមជាតិខន្តីអភ័យទោសឱ្យខ្ញុំព្រះករុណាខ្ញុំបាទដែលខ្វះសមត្ថភាពធ្វើជាម្ចាស់គ្រប់គ្រងលើទឹកដីនៃមាតុភូមិយើងហេតុនេះខ្ញុំត្រូវបញ្ចប់ជីវិតរបស់ខ្លួនខ្ញុំក្នុងពេលនេះ។ សូមប្រជារាស្ត្រខ្មែរទាំងអស់រស់



រូបថតចលនា ស្ទូខ្មែរក្រោម

ដើមឈើទាលដែលដាំគល់ឡើងលើ ចុងនៅក្នុងដីនៅកម្ពុជាក្រោម

នៅកុំបីមានវិប្បដិសារីទៅថ្ងៃក្រោយ,យួនបានយល់ព្រមឱ្យខ្មែរយើងថែរក្សាប្រពៃណី, ទំនៀមទម្លាប់ និងពុទ្ធសាសនាជារៀងរហូតតទៅ, ហេតុនេះសូមព្រះសង្ឃ និងជនរួមជាតិជួយថែរក្សា, ការពារកុំឱ្យអណ្តែតរសាត់ទៅតាមព្យុះសង្ឃរា, សូមចងចាំនិងយល់ពាក្យរបស់ខ្ញុំឱ្យបានច្បាស់: "ជនជាតិខ្មែរត្រូវប្រកាន់ខ្ជាប់នូវធម៌សាមគ្គីកុំឱ្យវិបល្លាសទៅតាមសត្រូវ និងនាំឱ្យហិនហោច និងបាត់បង់ជាតិឯង, កុំប្រើធម៌ក្បត់លក់ជាតិ និងសាសនា, ត្រូវខំតស៊ូទោះប្តូរជីវិតការពារនូវជាតិសាសនា,ជាក្តី ដ៏ណែលនេះឱ្យបានស្ថិតស្ថេរ, គង់វង្សជារៀងដរាប"តាំងពីពេលនោះមក, ប្រជារាស្ត្រខ្មែរក្រោមចងចាំជានិច្ចនៅពាក្យបណ្តាំរបស់ឧកញ៉ា សឺន គុយ ពី

**តទៅទំព័រទី ៣០**

KhmerPost USA ខ្មែរផុស

# ខ្មែរផុស ស.រ.អា

មានទទួលធ្វើការងារបន្ថែម



- កាសែត
- ទស្សនាវដ្តី
- Poster
- Banner
- ធៀបការ
- សំបុត្របុណ្យ
- នាមប័ណ្ណ
- ខួបកំណើត
- សំបុត្រឡើងគេហដ្ឋាន



សូមទាក់ទងមកតាមរយៈទូរស័ព្ទ:

Tel: 978-656-8141

Email: khmerpostusa@gmail.com

## តមកពីទំព័រទី ១៤ លោកស្រី ណាន ស៊ុ ភេឡូស៊ី...

យោងតាមសេចក្តីប្រកាសព័ត៌មានពីការិយាល័យរបស់លោកស្រី ភេឡូស៊ី បានឱ្យដឹងថា បន្ថែមទៅនឹងការមកបំពេញទស្សនកិច្ចនៅកម្ពុជាគណៈប្រតិភូនេះនឹងធ្វើទស្សនកិច្ចប្រទេសភូមា វៀតណាម កូរ៉េខាងត្បូង និងប្រទេសជប៉ុន។

លោកស្រី ភេឡូស៊ី និយាយក្នុងសេចក្តីប្រកាសព័ត៌មានថា "គណៈប្រតិភូរបស់យើងនឹងពិភាក្សាអំពីវិធីនានាដែលយើងអាចពង្រឹងកិច្ចសហប្រតិបត្តិការសន្តិសុខជំរុញសិទ្ធិមនុស្សដោយយកចិត្តទុកដាក់ខ្លាំងលើស្ត្រី កម្មករ ក្រុមសាសនាភាគតិច ហើយបង្កើនពាណិជ្ជកម្មត្រឹមត្រូវ"។

លោក ដ្រូ ហែមមីល អ្នកនាំពាក្យលោកស្រី ភេឡូស៊ី មិនបានឆ្លើយតបសំណើសុំការអត្ថាធិប្បាយទេ។

យោងតាមសេចក្តីប្រកាសព័ត៌មានបានឱ្យដឹងថា គណៈប្រតិភូពីរគណបក្សមានខាងគណបក្សប្រជាធិបតេយ្យ៩រូប និងខាងគណបក្សសាធារណរដ្ឋ១រូប ក៏នឹងស្វះស្វែងឱ្យមានការយល់ដឹងប្រសើរអំពីដៃគូឆ្លងកាត់មហាសមុទ្រប៉ាស៊ីហ្វិក អំឡុងដំណើរទស្សនកិច្ចនេះដែរ។

ដៃគូឆ្លងកាត់មហាសមុទ្រប៉ាស៊ីហ្វិកជាកិច្ចព្រមព្រៀងពាណិជ្ជកម្មដែលស្នើឡើងរវាងអាមេរិកនិងប្រទេស១១ផ្សេងទៀត ក្នុងនោះមានវៀតណាម និងជប៉ុនផងដែរ បានរងការរិះគន់ចំពោះភាពសម្ងាត់នៃការចរចារបស់ខ្លួន។

រហូតមកដល់ពេលនេះ ប្រទេសកម្ពុជាមិនទាន់បានចូលរួមក្នុងសន្ធិសញ្ញានេះទេ។

លោកស្រី ភេឡូស៊ី បានធ្វើការនៅសភាតាំងពីឆ្នាំ១៩៨៧មកម្ល៉េះ។ ក្នុងឆ្នាំ២០០៧ លោកស្រីបានក្លាយជាស្ត្រីទី១ធ្វើជាប្រធានសភាជាតំណែងដែលលោកស្រីបានកាន់រហូតដល់ឆ្នាំ២០១១។

ក្នុងអត្ថបទមួយអបអរខួបកំណើតទី៧៥របស់លោកស្រី ភេឡូស៊ី កាលពីថ្ងៃព្រហស្បតិ៍ កាសែតវ៉ាស៊ីនតោនប៉ុស្តិ៍បានពណ៌នាលោកស្រីថាជា "មេដឹកនាំមានប្រសិទ្ធភាពបំផុតក្នុងសភា"៕ **និត**

## តមកពីទំព័រទី ប្រវត្តិសង្ខេប "ទឹកដីកម្ពុជាក្រោម"...

ជំនាន់មួយទៅជំនាន់មួយ,មិនដែលបានទុកខ្លួនឯងថា:ជាជនជាតិវៀតណាមនោះឡើយ។ ព្រោះអ្វីៗនៅលើខ្លួនរបស់ពួកគេ គឺជាខ្មែរសុទ្ធសាធ,ទាំងវប្បធម៌, អក្សរសាស្ត្រ,ប្រពៃណី និងទំនៀមទំលាប់ពុទ្ធសាសនាខ្មែរ, រក្សាទុកជាកេរ្តិ៍ដំណែលពីដូនតាជារៀងរហូតមក។

នោះជាមូលហេតុបណ្តាលឱ្យរដ្ឋាភិបាលវៀតណាមកើតទុក្ខមិនសុខចិត្ត, ខិតខំរិះរកគ្រប់មធ្យោបាយដើម្បីអនុវត្តនូវទ្រឹស្តីនយោបាយ ហោ ជី មិញបានបង្គាប់ថា: "ប្រើពេល១០ឆ្នាំសម្រាប់ដាំកូនឈើ, ប្រើពេល១០០ឆ្នាំសម្រាប់បង្កើតមនុស្ស"នេះជាទ្រឹស្តីបញ្ចុះបញ្ចូល, លួងលោម, មានការពោលអួតគុណវិសេសសម្រាប់ជាតិ និងសាសនាខ្មែរ, ការបញ្ចើចសរសើរ, ការបោកប្រាស់ថា នឹងផ្តល់ផលប្រយោជន៍ដល់ជនជាតិខ្មែរជាដើម ។ល។

ទោះបីជាខំលួងលោមយ៉ាងណាក៏ដោយ, ក៏ខ្មែរក្រោមនៅតែមិនជឿទុកចិត្តជាដាច់ខាត, ម្លោះហើយរដ្ឋបាលវៀតណាម ក៏រកវិធីធ្វើទុក្ខបុកម្នេញ, គៀបសង្កត់, ចាប់ដាក់ពន្ធនាគារ, ចោទពីបទប្រឆាំង និងបក្សរួចសម្លាប់ក្នុងគុក, មានខ្លះត្រូវវាយស្ទើរស្លាប់ ដៃជើងខ្វិនប្រាណញ័រចំប្រប់ជាប់រហូតក្នុងរយៈពេលមួយឆ្នាំ ឬពីឆ្នាំក៏បាត់ជីវិតទៅដូចលោក ថាច់ស៊ាងនៅស្រុកថ្កូវ, ខេត្តព្រះត្រពាំង, ខ្លះទៀតបានចាប់យកទៅចាក់ប្រេងសាំងដុតទាំងរស់នៅខេត្ត ពល លៀវ និងខេត្តឃ្លាំង។

ភាពជាក់ស្តែងក្នុងអំឡុងឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៨៦, អាជ្ញាធមិវៀតណាមបានអនុវត្តផែនការណ៍បោសសម្អាត"កា...សេ៥០"(KC.50) បានចាប់ព្រះសង្ឃ និងបញ្ញវន្តខ្មែរក្រោមជាច្រើនឥតគណនាដាក់ក្នុងពន្ធនាគាធ្វើទារុណកម្មរហូតបាត់បង់ជីវិត, មានព្រះតេជគុណព្រះមេគណ គិម តុក ចើង,គ្រូបណ្ឌិត ថាច់ វ៉ាន នៅខេត្តព្រះត្រពាំង និងព្រះចៅអធិការ, ព្រះពហូសូត្រច្រើនរាប់មិនអស់,ខ្លះទៀតត្រូវឃុំខ្លួនក្នុងវត្តឬនៅក្នុងភូមិដោយឥតលក្ខណ,ឥតពេលកំណត់,ហាមមិនឱ្យខ្មែរក្រោមធ្វើដំណើរចេញក្រៅភូមិ,ហាមមិនឱ្យមានការជួបជុំគ្នាហួសពីបីនាក់ជាដើម។ នោះជាមូលហេតុនាំឱ្យខ្មែរក្រោមត្រូវស្លាប់ និងបាត់ខ្លួនដោយស្ងាត់ៗប្រមាណ២០%រហូតដល់សព្វថ្ងៃ ។

អ្វីដែលនាំឱ្យឈឺចាប់ជាងការស្លាប់នោះ គឺប្រជារាស្ត្រខ្មែរក្រោមកំពុងមានជីវិតរស់នៅបើកភ្នែកធំៗសម្លឹងមើលជនជាតិខ្មែរខ្លួនឯងកុំពុងធ្វើការបំរើផលប្រយោជន៍ឱ្យយួនដែលជាសត្រូវសម្លាប់បំផ្លាញជាតិឯង៕

**(និងមានចុះផ្សាយបន្តនៅលើកក្រោយ)**


# មជ្ឈមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល

LOWELL ELDER CARE 978-596-1111

**345 Chelmsford St. Lowell, MA 01851/ — www.lowelleldercare.com**

### អ្វីទៅជាមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល?

គឺជាលំនៅដ៏កក់ក្តៅមួយ ដែលផ្តល់សេវាមានកម្មវិធីជាក់លាក់ដល់សហគមន៍បំណង គឺគាំទ្រឲ្យមនុស្សចាស់ជរាអាចរស់នៅដោយឯករាជ្យខ្លួនឯង និងជួយឲ្យមានសុខុមាលភាពផ្នែកផ្លូវកាយ ផ្លូវចិត្ត និងផ្នែកសង្គម ។ កម្មវិធីរបស់យើងធានានូវបរិស្ថានរស់នៅមួយប្រកបដោយសុវត្ថិភាព និងមានបរិយាកាសដូចជាផ្ទះរបស់ពួកគាត់ ។

### ទីតាំងនៃមណ្ឌល

ទីតាំងអាចរកឃើញដោយងាយក្នុងអគារថ្មី ជាមួយនូវការតុបតែងរចនាបែបសិល្បៈខ្មែរយ៉ាងល្អប្រណិត ។ មានបន្ទប់ទទួលទានអាហារស្អាត និងមានពន្លឺគ្រប់គ្រាន់ បន្ទប់អានសៀវភៅ បន្ទប់កុំព្យូទ័រ បន្ទប់សម្រាក បន្ទប់មើលភាពយន្ត និងកន្លែងផ្សេងៗទៀតជាទីពេញចិត្តរបស់លោកអ្នក ។

### មណ្ឌលផ្តល់សេវាដល់មនុស្សចាស់

- មានរថយន្តជូនដំណើរទៅវិញទៅមកពីផ្ទះលោកអ្នក
- ការពិនិត្យ និងថែទាំសុខភាព
- ការព្យាបាលតាមរយៈការហាត់ប្រាណ
- កិច្ចការសង្គម (ផ្តល់ការពិគ្រោះផ្ទាល់ខ្លួន និងក្រុមគ្រួសារ)
- ម្ហូបខ្មែរក្តៅៗ និងចំណីផ្សេងៗ
- ការហាត់ប្រាណសំរាប់សុខភាពរាងកាយ
- កម្មវិធីសិល្បៈ និងតន្ត្រី
- ការអប់រំពីសុខភាព
- ការពិភាក្សាលើព្រឹត្តិការបច្ចុប្បន្ន (និងការសំណេះសំណាលគ្នា)
- សកម្មភាព និងដំណើរកំសាន្តក្រៅមណ្ឌល

### Our Services

- Door-to-Door Transportation
- Medical Care and Support
- Physical Therapy
- Social Worker
- Khmer Meals and Snacks
- Adaptive Physical Exercise
- Music Programs
- Health Educational Seminars
- Discussions on current events, (and times of reminiscing)
- Outdoor Field Trips





**សូមហៅលេខទូរស័ព្ទ (978) 596-1111**

## តមកពីទំព័រទី ០១ ឆ្នាំមមែក្នុងទំនាយមហាសង្ក្រាន្ត...

ត្រូវនឹងថ្ងៃទី១៤ ខែមេសា វេលាម៉ោង ១៤ និង០២នាទីរសៀល ។ ចំណែកទេវតាឆ្នាំថ្មីដែលនឹងមកទទួលតំណែងរក្សាសត្វលោកនាឋានកណ្តាលយើង នេះគឺជារាជបុត្រីទី៣របស់កបិលមហាព្រហ្មព្រះនាងជាមត្តនាយិកាព្រះនាមរាក្សសៈទេវី ។

ដើម្បីឱ្យមានជោគសិរីសួស្តីចូលមានដល់ជនគ្រប់រូបនាឆ្នាំថ្មីនេះ ក្រៅអំពីការរៀបចំបោសសំអាតផ្ទះ និងតុបតែងលំនៅឋានត្រូវត្រៀមលក្ខណៈទទួលព្រះនាងរាក្សសៈ ទេវីជាទេវតា ឆ្នាំមមែ ដែលនឹងហែហមដោយបរិវារជាទេពធីតា និងទេពនិករប្រមាណមួយសែនកោដិ ។ ព្រះនាង ទេពធីតា ទ្រង់អម្ពរពណ៌ខ្មៅមានសៀត ព្រះកាណ៌ (ត្រចៀក) ដោយផ្កាឈូក ទ្រង់ពាក់ កែវមនោរា និងសោយលោហិត ជាភក្សាហារ ។ ព្រះហស្តឆ្វេងទ្រង់ធ្នូឯព្រះហស្តស្តាំទ្រង់ត្រីសូល ។ ទ្រង់គង់លើខ្នងអស្សតរ (សេះ) ជាជំនិះ ។

ចំពោះរណ្តាប់ និងរបៀបរៀបចំទទួលទេវតាឆ្នាំថ្មី គឺត្រូវរៀបចំធ្វើនៅចំមុខផ្ទះដោយក្រាល សំពត់ពណ៌សមានរៀបបាយសី៩ថ្នាក់១គូ បាយសី ៧ថ្នាក់១គូ បាយសី៥ថ្នាក់១គូ បាយសី៣ថ្នាក់១គូ ប៉ាឆាម១គូ ស្លាធម៌១គូ



ទឹកអប់១គូ ទៀន៥ ធូប៥ លាជ៥ ផ្កា៥ដាក់លើជើងពាន១គូ ចេកនួន ចេកណាំវ៉ាដាក់២ជើងពាន ផ្លែឈើ១១មុខ ដាក់លើជើងពាន ១១គូ ដូងខ្ចី១គូ និងទឹកស្អាត២កែវ ។ លុះនៅវេលាម៉ោងដែលទេវតាចុះមកត្រូវជួបប្រជុំក្រុមគ្រួសារដើម្បីថ្វាយបង្គំព្រះនមស្ការព្រះរត្នត្រ័យសមាទានសីល ហើយតាំងចិត្តឱ្យបានស្អាតបរិសុទ្ធជ្រះស្រឡះនូវមន្ទិលទាំងពួងតម្កល់ចិត្តរំពឹងគិតទៅលើព្រះពុទ្ធ ព្រះធម៌ព្រះសង្ឃជាទីពឹងរហូតចប់ពិធីទទួលទេវតា ។

នៅក្នុងមហាសង្ក្រាន្តមានគណនាតាំងពីទឹកភ្លៀងពីផលដំណាំ ការធ្វើស្រែចំការ និងមានតម្រាប្រចាំថ្ងៃ និងព្យាករណ៍ពីជោគជតារាសី តាមថ្ងៃ-ខែ-ឆ្នាំកំណើតផងដែរ ។

ចំពោះការគណនាអំពីទឹកភ្លៀងសម្រាប់ឆ្នាំថ្មីនេះ ទំនាយថា នឹងមាននាគពាមកបង្អុរភ្លៀង៤០០មេ ចែកមកឱ្យចក្រវាល១៦០មេ ព្រៃហេមពាន្ត១២០មេ មហាសមុទ្រ៨០មេ និងចែកមកជម្ពូទ្វីបឋានកណ្តាលមនុស្សលោកយើងចំនួន៤០មេ ។ រីឯផលដំណាំវិញ ឆ្នាំនេះត្រូវចំកេណ្ឌ០ (សូន្យ) មានឈ្មោះថា បាប ទំនាយថា ៖ ស្រូវ ដំណាំស្រែចម្ការបានផលពាក់កណ្តាល ខូចពាក់កណ្តាល ។ ប្រជារាស្ត្របានសុខ និងទុក្ខ និងស្មើគ្នា ។ ចំណែកឯកេណ្ឌព្រះអាទិត្យឆ្នាំនេះ ព្រះអាទិត្យធ្វើដំណើរជិះដីរ ទំនាយថា ៖ ភ្លើងកាចសាហាវ ។ ស្រុកនាមនាគធ្វើសង្គ្រាម និងស្រុកនាមគ្រុឌ និងនាមកណ្ដុរ ។

អំពីទំនាយថ្ងៃតាមសង្ក្រាន្តវិញ ចូលឆ្នាំថ្ងៃ ទី១ចំថ្ងៃចន្ទ ជាថ្ងៃដែលទំនាយថា ឆ្នាំនេះនឹងកើតអន្តរាយកណ្តាលទីក្រុងមានភ្លើងឆេះយ៉ាងសាហាវកើតនូវចោរចិត្តកាចច្រើនឡើងមនុស្សនឹងប្រែជាមានចិត្តអាក្រក់ ហើយមានជំងឺតម្កាត់ច្រើនជាទីបំផុត ។

**តទៅលេខក្រោយ**

## តមកពីទំព័រទី ១៧ វត្តព្រះពុទ្ធរង្សី...

**វិស័យប្រាជ្ញា:** កូនសិស្សត្រូវមានការរីកចំរើនជាប់ជានិច្ចលើវិស័យប្រាជ្ញា. ក្នុងខណះដែលកូនសិស្សណាមិនទាន់មានការស្ទាត់ជំនាញភាសាអង់គ្លេស និងត្រូវប្តូរទៅប្រើភាសាអង់គ្លេសតែមួយគាត់នោះ. និងធ្វើឱ្យប្រាជ្ញារបស់ពួកគេមានដំណើរការក្មេងខ្ចីជាងអាយុរបស់ខ្លួន. ព្រោះភាពវិវឌ្ឍន៍នៃប្រាជ្ញាមិនបានខ្ជាប់ខ្ជួន. នេះជាលក្ខណ:កង្វះការសិក្សាអប់រំ□ទោះបីជាយ៉ាងនោះក៏ដោយ. ពេលដែលកូនៗនិយាយទៅកាន់ឪពុកម្តាយគេអាចស្តាប់ និងយល់គ្នាបាន. ពួកគេ និងធ្វើការជាមួយគ្នាក្នុងភាពជាក់ស្តែងដោយបញ្ហាធំពេញវ័យ ។

**ផ្នែកសិក្សាអប់រំ:** ចំនួនកូនសិស្សដែលបានរៀនអង់គ្លេសបណ្តើរជាមួយអក្សរសាស្ត្រដើមកំណើតរបស់ខ្លួនមានអាត្រានៃភាពជោគជ័យលើវិស័យសិក្សាអប់រំមានកំរិតខ្ពស់ជាងចំនួនសិស្សដែលប្រើភាសាដើមតែមួយគាត់ ។

**ផ្នែកសេដ្ឋកិច្ច:** ភាពងាយស្រួលក្នុងឱកាសរកការធ្វើនៅក្នុងនិងក្រៅប្រទេស.ដែលអាចរកបានដោយឡែក. ចំពោះអ្នកចេះអង់គ្លេសជ្រៅជ្រះរួមជាមួយនិងភាសាដទៃទៀតផង ។

ថ្នាក់រៀនអក្សរខ្មែរ និងមានបើកនៅវត្ត ព្រះពុទ្ធរង្សី (2400 S.6th. Street, Philadelphia, PA 19148) រៀងរាល់ថ្ងៃសៅរ៍វេលាម៉ោង១:៣០នាទីរសៀល. សូមអញ្ជើញចូលដោយសេរី. ព័ត៌មានបន្ថែមទូរស័ព្ទលេខ (215) 939-9968.


សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ KhmerPost USA

IN PRINT. ONLINE
www.khmerpostusa.com

a free local newspaper reaching over 20,000 Cambodian readers in the Greater Lowell area every two weeks
Sample of our affordable pricing បញ្ជីតម្លៃពាណិជ្ជកម្មក្នុងតម្លៃសមរម្យ

| Page Size | Length x Width | 1 month 10%OFF |
|---|---|---|
| 1/2 page color | (6.5"x10") | $484 |
| 1/4 page color | (6.5"x5") | $264 |
| 1/8 Classify ad | (3.25"x5") | $100 |
| Business Card | | $50 |

Our 2015 Publishing Dates កាលវិភាគបោះពុម្ព

| | |
|---|---|
| April | 24th |
| May | 1st & 22nd |
| June | 5th & 26th |

*all ad materials are due one week prior to publishing date.
រាល់គំរូពាណិជ្ជកម្មត្រូវបញ្ជូនសប្តាហ៍មុនចូលរោងពុម្ព



Call or Visit our Sales Office
45 Merrimack Street, Suite 218A, Lowell, MA 01852
Tel: 978.677.7163. Cell: 978. 656.8141 Fax: 978.677.7092
Email: sobenpin@khmerpost.us or KhmerPostUSA@gmail.com
www.khmerpost.us | www.facebook.com/KhmerPostUSA




## កុំស្មានបងភ្លេច ខ្មែរបាត់បង់តន្ត្រីរ៉ក់

"ការរុករកឃើញ មរតកចំរៀងកម្ពុជា នាអំឡុងទសវត្សរ៍ឆ្នាំ១៩៦០ និង ១៩៧០" -ខេមបូឌា ដេលី

**បញ្ចាំងនៅរោងភាពយន្ត សូខេស ស៊ីនីម៉ា**

32 Reiss Ave, Lowell

ទីក្រុងឡូវ៉ើល រដ្ឋម៉ាស់សាឈូសេត សហរដ្ឋអាមេរិក

**ថ្ងៃសុក្រ ២៤ មេសា ២០១៥**

កម្មវិធីសំនួរចំលើយពី អ្នកដឹកនាំរឿង ចន ភីរ៉ូស៊ី និង មានការចូលរួមពីសំណាក់តន្ត្រីករផងដែរ

ថ្ងៃសៅរ៍ ២៥ មេសា នៅម៉ោង ៧យប់ និង

ថ្ងៃអាទិត្យ ២៦ មេសា នៅម៉ោង ៣:៣០ រសៀល

ពត៌មានបន្ថែមអំពីការបញ្ចាំង និង សំបុត្រចូលទស្សនា លោកអ្នកអាចទិញសំបុត្រដោយផ្ទាល់ នៅរោងភាពយន្ត **សូខេស ស៊ីនីម៉ា រឺ អាចរកទិញបានតាមរយៈវេបសាយ**

**showcasecinemas.com**

DON'T THINK I'VE FORGOTTEN: The Concert

**ថ្ងៃអាទិត្យ ២៦ មេសា ២០១៥** ម៉ោង ៦ល្ងាច

ការប្រគុំតន្ត្រីនៅភោជនីយដ្ឋានសំពៅមាស

៤៥០ ផ្លូវឆែមហ្វដ ទីក្រុងឡូវ៉ើល

៦:៣០ ល្ងាច ពិសាភោជនីយហារ

៧:៣០ ល្ងាច ប្រគំតន្ត្រីដោយ ក្រុមបក្សីចាំក្រុង និង ក្រុមដ្រាកា បទចំរៀងរបស់អ្នកនាងរស់ សេរីសុទ្ធា និង លោកស៊ីន ស៊ីសាមុត នឹងត្រូវច្រៀងឡើងវិញដោយកញ្ញាឆោម និមល និងលោកស៊ីន សេដ្ឋកុល ដែលជាចៅប្រុសរបស់លោក ស៊ីន ស៊ីសាមុត

តម្លៃសំបុត្រៈ ៣០ដុល្លារ (រួមបញ្ចូលម្ហូបខ្មែរបួនមុខ)

លោកអ្នកអាចទិញសំបុត្រដោយផ្ទាល់នៅ

Khmer Post USA, 45 Merrimack St., Suite 218A

រឺ អាចរកទិញបានតាមរយៈវេបសាយ tinyurl.com/lmlt2qt

**OPENS APRIL 24, 2015**

## Showcase Cinemas

32 Reiss Ave, Lowell

Fri 4/24: 11:00, 1:40, 4:20, 7:00, 9:40, 12:15
Sat 4/25: 11:00, 1:40, 4:20, 7:00, 10:15
Sun 4/26: 12:30, 3:30, 7:00, 9:40
Mon-Thu: 11:00, 1:40, 4:20, 7:00, 9:40

Director John Pirozzi and special musical guests:
Sat 4/25 at 7pm & Sun 4/26 at 3:30pm
Purchase tickets in person at Showcase Cinemas or online at **www.showcasecinemas.com**

*A vibrant musical culture that was nearly lost forever is revived and celebrated in this powerful new documentary.*

**SEE THE TRAILER**

www.youtube.com/watch?v=Ipq4FefX5Ps

www.argotpictures.com/dtif.html
www.dtifcambodia.com

**SUNDAY, APRIL 26, 2015**

DTIF Concert at Sompao Meas Hall

Featuring Baksey Cham Krong, The Drakkar, the songs of Ros Serey Sothea performed by Chhom Nimol, and the songs of Sinn Sisamouth performed by his grandson, Sinn Sethakol.
Four-course Cambodian dinner included for $30!
Doors at 6pm, Dinner at 6:30pm, Concert at 7:30pm

**Buy tickets in person at Khmer Post USA, 45 Merrimack St., Suite 218A or online at www.tinyurl.com/lmlt2qt**